00942418

លេខ: D121/4

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

Kingdom of Cambodia
Nation Religion King

Royaume du Cambodge
Nation Religion Roi

អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា

Extraordinary Chambers in the Courts of Cambodia
Chambres extraordinaires au sein des Tribunaux cambodgiens

---

ការិយាល័យសហចៅក្រមស៊ើបអង្កេត

**Office of the Co-Investigating Judges**
**Bureau des co-juges d'instruction**

| ឯកសារដើម |
|---|
| DOCUMENT RECEIVED/DOCUMENT REÇU |
| ថ្ងៃ ខែ ឆ្នាំ (Date of receipt/Date de reception): 31 / 07 / 2013 |
| ម៉ោង (Time/Heure): 14 : 30 |
| មន្ត្រីទទួលបន្ទុកសំណុំរឿង/Case File Officer/L'agent chargé du dossier: UCH ARUN |

លេខសំណុំរឿង: ០០៤/០៧-០៩-២០០៩/អ.វ.ត.ក.--ក.ស.ច.ស

ចំពោះមុខ ៖ សហចៅក្រមស៊ើបអង្កេត

កាលបរិច្ឆេទ ៖ ថ្ងៃទី ៣១ ខែ កក្កដា ឆ្នាំ ២០១៣

ភាសា ៖ ខ្មែរ/អង់គ្លេស [អង់គ្លេស ជាភាសាដើម]

ចំណាត់ថ្នាក់ឯកសារ ៖ សាធារណៈ

---

# សេចក្តីសម្រេចលើសំណើរបស់ក្រុមការពារក្តីកាសលុបសុំចូលពិនិត្យមើលសំណុំរឿង និងចូលរួមការស៊ើបអង្កេត

---

**ផ្ញើជូន៖**

**សហព្រះរាជអាជ្ញា**

ជា លាង
Andrew CAYLEY

**ជូនចំពោះ៖**

**មេធាវីជនសង្ស័យ**

ម៉ុំ លុច្ឆ
Göran SLUITER

**សហមេធាវីដើមបណ្តឹងរដ្ឋប្បវេណី**

ជេត វណ្ណលី
ហុង គីមសួន
គីម ម៉េងឃី
គង់ ផល្លៈ
ឡោ ជុនធី
សំ សុគង់
ទី ស្រីនណា
វ៉ែន ពៅ

Annie DELAHAIE
Laure DESFORGES
Ferdinand DJAMMEN-NZEPA
Nicole DUMAS
Isabelle DURAND
Françoise GAUTRY
Martine JACQUIN
Emmanuel JACOMY
Christine MARTINEAU
Mahdev MOHAN
Barnabe NEKUI
Lyma NGUYEN
Philippine SUTZ

1. **បានឃើញ** កិច្ចព្រមព្រៀងរវាងអង្គការសហប្រជាជាតិ និងរាជរដ្ឋាភិបាលកម្ពុជាទាក់ទងនឹងការកាត់សេចក្តីនៅក្រោមច្បាប់កម្ពុជា នូវឧក្រិដ្ឋកម្មដែលប្រព្រឹត្តឡើងនៅក្នុងរយៈកាលនៃកម្ពុជាប្រជាធិបតេយ្យ ចុះថ្ងៃទី ៦ ខែ មិថុនា ឆ្នាំ២០០៣ ( "កិច្ចព្រមព្រៀង អ.វ.ត.ក")។

2. **បានឃើញ** ច្បាប់ស្តីពីការបង្កើតអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ចុះថ្ងៃទី ២៧ ខែ តុលា ឆ្នាំ ២០០៤ ("ច្បាប់ស្តីពីការបង្កើត អ.វ.ត.ក")។

3. **បានឃើញ** ដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរលើកទី៣ ចុះថ្ងៃទី ២០ ខែ វិច្ឆិកា ឆ្នាំ ២០០៨ ទាក់ទងនឹងសំណុំរឿង០០៤[១] ដែលត្រូវបានដាក់ចូលទៅក្នុងសំណុំរឿង នៅថ្ងៃទី ៧ ខែ កញ្ញា ឆ្នាំ ២០០៩[២]។

4. **បានឃើញ** ដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរបន្ថែម ទាក់ទងនឹងទីតាំងឧក្រិដ្ឋកម្មនានានៅក្នុងតំបន់ ១ និងការធ្វើទុក្ខបុកម្នេញចំពោះខ្មែរក្រោម ទាក់ទងនឹងសំណុំរឿង ០០៤ ចុះថ្ងៃទី ១៨ ខែ កក្កដា ឆ្នាំ ២០១១[3]។

5. **បានឃើញ** ការបើកកិច្ចស៊ើបសួរទាក់ទងនឹងបទចោទប្រកាន់អំពីការរំលោភបំពានលើ**ក្រមព្រហ្មទណ្ឌ ឆ្នាំ ១៩៥៦** ការរំលោភបំពានលើ**អនុសញ្ញាស្តីពីការទប់ស្កាត់ និងផ្តន្ទាទោសចំពោះអំពើឧក្រិដ្ឋកម្មប្រល័យពូជសាសន៍ អនុសញ្ញាក្រុងហ្សឺណែវ ១៩៤៩** ព្រមទាំងទាក់ទងនឹង**ឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ** ដែលត្រូវផ្តន្ទាទោសតាមមាត្រា ៣(ថ្មី), ៤, ៥,៦, ២៩(ថ្មី)

---

[១] សំណុំរឿង ០០៤ ឯកសារ D1 *ដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរលើកទី៣របស់សហព្រះរាជអាជ្ញា* ចុះថ្ងៃទី ២០ ខែ វិច្ឆិកា ឆ្នាំ ២០០៨ ។

[២] សំណុំរឿង ០០៤ ឯកសារ D1/1 *ការជូនដំណឹងអំពីការដាក់ដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរលើកទី៣របស់សហព្រះរាជអាជ្ញាអន្តរជាតិស្តីទី* ចុះថ្ងៃទី ៧ ខែ កញ្ញា ឆ្នាំ ២០០៩ ។

[3] សំណុំរឿង ០០៤ ឯកសារ D65 *ដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរបន្ថែមរបស់សហព្រះរាជអាជ្ញាទាក់ទងទៅនឹងទីតាំងឧក្រិដ្ឋកម្មនានានៅក្នុងតំបន់ ១ និងការធ្វើទុក្ខបុកម្នេញចំពោះខ្មែរក្រោម* ចុះថ្ងៃទី ១៨ ខែ កក្កដា ឆ្នាំ ២០១១។

និង៣៩(ថ្មី) នៃច្បាប់ស្តីពីការបង្កើត អ.វ.ត.ក ព្រមទាំងមាត្រា ២០៩, ២១០, ៥០០, ៥០១, ៥០៣, ៥០៤, ៥០៥, ៥០៦, ៥០៧, និង ៥០៨ នៃក្រមព្រហ្មទណ្ឌ ឆ្នាំ ១៩៥៦ ។

6. **បានឃើញ** វិធាន ២១, ៥៥, ៥៧, ៦០ និង ៨៦ នៃវិធានផ្ទៃក្នុងរបស់អ.វ.ត.ក វិសោធនកម្មលើកទី ៨ ("វិធានផ្ទៃក្នុង")។

7. **បានឃើញ**ថា នៅថ្ងៃទី ២២ ខែ កុម្ភៈ ឆ្នាំ ២០១៣ ចៅក្រម យូ ប៊ុនឡេង ("សហចៅក្រមស៊ើបអង្កេតជាតិ") និងសហចៅក្រមស៊ើបអង្កេតអន្តរជាតិ បានចុះហត្ថលេខាលើកំណត់ហេតុនៃករណីខ្វែងយោបល់គ្នា ពាក់ព័ន្ធដូចជា បញ្ហានេះ។

## ក. ប្រវត្តិនីតិវិធី

8. នៅថ្ងៃទី ២៩ ខែ កក្កដា ឆ្នាំ ២០១០ លោក Richard Rogers បានដាក់លិខិតមួយជូនទៅសហព្រះរាជអាជ្ញា ដោយស្នើសុំក្នុងនាមជាប្រធានអង្គភាពគាំពារការពារក្តី ("អ.គ.ក") ចូលពិនិត្យមើលសំណុំរឿងសម្រាប់ជនសង្ស័យនៅក្នុងសំណុំរឿង ០០៣ និង ០០៤ និងស្នើសុំសិទ្ធិនីតិវិធីផ្សេងទៀត រួមមានសិទ្ធិដូចបានបញ្ជាក់នៅក្នុងវិធានផ្ទៃក្នុង ៥៥(៨) និង ៥៥(១០) ដែលត្រូវបានអះអាងថាចាំបាច់ត្រូវមានដើម្បីធានាឲ្យមានការការពារសិទ្ធិដូចមានចែងនៅក្នុងវិធានផ្ទៃក្នុង ២១។ នៅក្នុងលិខិតនេះ ប្រធាន អ.គ.ក បានលើកឡើងពីសេចក្តីព្រួយបារម្ភស្តីពីស្ថានភាពរបស់ជនសង្ស័យនៅក្នុងសំណុំរឿង ០០៣ និង ០០៤ ("ជនសង្ស័យ")ដែលលិខិតនេះបានអះអាងថា *"ត្រូវបានទុកចោលដោយគ្មានតំណាងផ្នែកច្បាប់ក្នុងរូបភាពណាមួយ ឬមធ្យោបាយណាមួយដើម្បីការពារសិទ្ធិទទួលបានការជំនុំជម្រះក្តីដោយយុត្តិធម៌ឡើយ ទោះបីជាពួកគេទទួលរងផលប៉ះពាល់យ៉ាងធ្ងន់ធ្ងរពីការស៊ើបអង្កេតក៏ដោយ"*[៤]។ នៅថ្ងៃទី ២០ ខែ កញ្ញា ឆ្នាំ ២០១០ អ.គ.ក បានដាក់សារណាបន្ថែមទៀតលើចំណុចនេះ ដោយបញ្ជាក់ដូចជា "លទ្ធភាពនៃការប៉ះពាល់ដល់សិទ្ធិទទួលបានការជំនុំជម្រះក្តីដោយយុត្តិធម៌របស់ជនសង្ស័យ

---

[៤] សំណុំរឿង ០០៤ ឯកសារ D4.1.29 *លិខិតរបស់អង្គភាពគាំពារការពារក្តីស្តីពីសិទ្ធិការពារក្តីនៅក្នុងសំណុំរឿង ០០៣ និង ០០៤* ចុះថ្ងៃទី ២៩ ខែ កក្កដា ឆ្នាំ ២០១០។

អនាមិក” កំពុងចេះតែកើនឡើងដោយសារកង្វះខាតមិនមានការចម្លើយតបទាន់ពេលវេលាពីសហចៅក្រមស៊ើបអង្កេត [5]។

9. នៅថ្ងៃទី ២៣ ខែ កញ្ញា ឆ្នាំ ២០១០ សហចៅក្រមស៊ើបអង្កេត បានឆ្លើយតបទៅ អ.គ.ក ដោយពន្យល់ពីមូលហេតុរបស់ខ្លួនដែលមិនផ្តល់ឱ្យជនសង្ស័យនូវការអនុញ្ញាតចូលពិនិត្យមើលសំណុំរឿង ០០៣ និង ០០៤។ សហចៅក្រមស៊ើបអង្កេត បានបញ្ជាក់ដូចជា *“សិទ្ធិការពារក្តីអាចអនុវត្តបានយ៉ាងពេញលេញ (ហើយគោលការណ៍សមភាពនៃមធ្យោបាយតទល់រឿងក្តីត្រូវតែគោរពយ៉ាងខ្ជាប់ខ្ជួននៅពេលដែលជនម្នាក់ត្រូវបានចោទប្រកាន់ ហើយ ក្លាយជាភាគីនៃកិច្ចដំណើរការនីតិវិធី។ ប៉ុន្តែ ដរាបណាជនណាម្នាក់មិនត្រូវបានចោទប្រកាន់ជាផ្លូវការ សិទ្ធិរបស់ជននោះនៅមានកម្រិតនៅឡើយ។ នេះគឺជាករណីដែលអនុវត្តនៅគ្រប់ ប្រព័ន្ធនីតិវិធីទាំងអស់”* [6]។

10. នៅថ្ងៃទី ៨ ខែ វិច្ឆិកា ឆ្នាំ ២០១០ អ.គ.ក បានសម្រេចចាត់តាំងមេធាវីកម្ពុជាម្នាក់ឈ្មោះ គង់ សំអុន ឱ្យតំណាងផលប្រយោជន៍របស់ជនសង្ស័យ។ បើយោងតាម អ.គ.ក សេចក្តីសម្រេចនេះត្រូវបានធ្វើឡើងដោយផ្អែកលើមូលដ្ឋាននៃសិទ្ធិរបស់ជនសង្ស័យទទួលបានមេធាវី ដោយខានមិនបាន និងករណីយកិច្ច និងអំណាចរបស់របស់ អ.គ.ក ក្នុងការចាត់តាំងមេធាវីឱ្យជនសង្ស័យ [7] ។ នៅថ្ងៃទី ១១ ខែ កុម្ភៈ ឆ្នាំ ២០១១ អ.គ.ក បានជូនដំណឹងអំពីការចាត់តាំងនេះទៅសហចៅក្រមស៊ើបអង្កេត[8] ។

11. នៅថ្ងៃទី ១៤ ខែ កុម្ភៈ ឆ្នាំ ២០១១ លោក គង់ សំអុន បានដាក់*សំណើពិនិត្យសំណុំរឿង ០០៣ និង ០០៤* ដោយទាមទារចូលពិនិត្យមើលសំណុំរឿង ឬក៏ស្នើសហចៅក្រមស៊ើបអង្កេត សុំ

---

[5] សំណុំរឿង ០០៤ ឯកសារ A1/1 *លិខិតរំឭករបស់អង្គភាពគាំពារការពារក្តីស្តីពីសិទ្ធិការពារក្តីនៅក្នុងសំណុំរឿង ០០៣ និង ០០៤* ថ្ងៃទី ២០ ខែ កញ្ញា ឆ្នាំ ២០១០។

[6] សំណុំរឿង ០០៤ ឯកសារ D4.1.31 *ចម្លើយតបរបស់ ស.ចៅ.ស ស្តីពីសិទ្ធិការពារក្តីនៅក្នុងសំណុំរឿងលេខ ០០៣ និង ០០៤* ចុះថ្ងៃទី ២៣ ខែ កញ្ញា ឆ្នាំ ២០១០ (“ចម្លើយតបរបស់ ស.ចៅ.ស ចុះថ្ងៃទី ២៣ ខែ កញ្ញា ឆ្នាំ ២០១០”) ទំព័រ ១។

[7] សំណុំរឿង ០០៤ ឯកសារ A2 *ការជូនដំណឹងពីការចាត់តាំងមេធាវី-សំណុំរឿង ០០៣ និង ០០៤* ចុះថ្ងៃទី ១១ ខែ កុម្ភៈ ឆ្នាំ ២០១១ កថាខណ្ឌ ៥។

[8] ដូចចុងទំព័រខាងលើ កថាខណ្ឌ ១។

លុបចោលកិច្ចដំណើរការនីតិវិធីប្រឆាំងនឹងជនសង្ស័យ [9]។ លោក គង់ សំអុន បានយកសំណើរបស់គាត់ផ្អែកលើមូលដ្ឋាននៃគោលការណ៍សមភាពនៃមធ្យោបាយតទល់រឿងក្តី និងសិទ្ធិទទួលបានការជំនុំជម្រះក្តីដោយយុត្តិធម៌ ដែលករណីនេះ គាត់បានអះអាងថា យកមកអនុវត្តចាប់តាំងពីពេលដែលផលប្រយោជន៍របស់ជនសង្ស័យ "ត្រូវបានប៉ះពាល់ជាដុំកំភួន"[10] ។ នៅក្នុងសំណើរបស់លោក គង់ សំអុន សមត្ថភាពរបស់ក្រុមការពារក្តីដែលមិនអាចតាមដានការស៊ើប អង្កេត និងរៀបចំការការពារក្តីឲ្យបានប្រសិទ្ធភាព គឺបានប៉ះពាល់ដល់ជនសាក្សីយ៉ាងខ្លាំង[11] ។

12. នៅថ្ងៃទី ៥ ខែ មេសា ឆ្នាំ ២០១១ សហចៅក្រមស៊ើបអង្កេត បានចេញ *ដីកាសម្រេចលើសំណើសុំមើលសំណុំរឿងលេខ ០០៣ និង ០០៤* (ដីកាសម្រេច ចុះថ្ងៃទី ៥ ខែ មេសា ឆ្នាំ ២០១១) ដោយច្រានចោលសំណើនេះ ដោយផ្អែកលើមូលដ្ឋានថា ជនសង្ស័យ មិនត្រូវបានចោទតាមរយៈនីតិវិធីផ្លូវការដូចមានចែងនៅក្នុងវិធានផ្ទៃក្នុង ៥៧ ហើយ ផលប្រយោជន៍របស់ជនសង្ស័យក៏មិនត្រូវបានប៉ះពាល់ធ្ងន់ធ្ងរដោយសារការស៊ើបអង្កេតដែរ [12] ។ ទាក់ទងនឹងសេចក្តីសន្និដ្ឋានដែលថា ការស៊ើបអង្កេត មិនបានប៉ះពាល់ធ្ងន់ធ្ងរដល់ជនសង្ស័យ សហចៅក្រមស៊ើបអង្កេត បានបញ្ជាក់ថា គ្មានជនសង្ស័យណាម្នាក់ត្រូវបានគេទាក់ទង សួរយកចម្លើយ ក្លាយជាកម្មវត្ថុនៃការឆែកឆេរ និងការរឹបអូស ឃុំខ្លួន ឬ ត្រូវទទួលរងការប៉ះពាល់តាមវិធីដទៃទៀត ដោយការស៊ើបសួររបស់សហចៅក្រមស៊ើបអង្កេតឡើយ [13]។

---

[9] សំណុំរឿង ០០៤ ឯកសារ D4 *សំណើពិនិត្យសំណុំរឿង ០០៣ និង ០០៤* ចុះថ្ងៃទី ១៤ ខែ កុម្ភៈ ឆ្នាំ ២០១១ កថាខណ្ឌ ៤៤។

[10] សំណុំរឿង ០០៤ ឯកសារ D4 *សំណើពិនិត្យសំណុំរឿង ០០៣ និង ០០៤* ចុះថ្ងៃទី ១៤ ខែ កុម្ភៈ ឆ្នាំ ២០១១ កថាខណ្ឌ ១៨-២២។

[11] សំណុំរឿង ០០៤ ឯកសារ D4 *សំណើពិនិត្យសំណុំរឿង ០០៣ និង ០០៤* ចុះថ្ងៃទី ១៤ ខែ កុម្ភៈ ឆ្នាំ ២០១១ កថាខណ្ឌ ២៨ និង ៣៨។

[12] សំណុំរឿង ០០៤ ឯកសារ D4/1 *ដីកាសម្រេចលើសំណើសុំមើលសំណុំរឿងលេខ ០០៣ និង ០០៤* ចុះថ្ងៃទី ៥ ខែ មេសា ឆ្នាំ ២០១១ ("ដីកាសម្រេចចុះថ្ងៃទី ៥ ខែ មេសា ឆ្នាំ ២០១១") កថាខណ្ឌ ៣-៨ និង ១២-១៣។

[13] សំណុំរឿង ០០៤ ឯកសារ D4/1 *ដីកាសម្រេចលើសំណើសុំមើលសំណុំរឿងលេខ ០០៣ និង ០០៤* ចុះថ្ងៃទី ៥ ខែ មេសា ឆ្នាំ ២០១១ ("ដីកាសម្រេចចុះថ្ងៃទី ៥ ខែ មេសា ឆ្នាំ ២០១១") កថាខណ្ឌ ៨។

13. នៅថ្ងៃទី ២៩ ខែ មេសា ឆ្នាំ ២០១១ លោក គង់ សំអុន បានដាក់*សំណើពិនិត្យឡើងវិញនូវដីកាសម្រេចលើសំណើរបស់មេធាវីការពារក្តី សុំពិនិត្យមើលសំណុំរឿងលេខ ០០៣ និង លេខ ០០៤ ចុះថ្ងៃទី ៥ ខែ មេសា ឆ្នាំ ២០១១* ("សំណើចុះថ្ងៃទី ២៩ ខែ មេសា ឆ្នាំ ២០១១") ជូនទៅសហចៅក្រមស៊ើបអង្កេត ដោយស្នើសុំពិចារណាឡើងវិញលើដីកាសម្រេច ចុះថ្ងៃទី ៥ ខែ មេសា ឆ្នាំ ២០១១ និងសុំការអនុញ្ញាតចូលពិនិត្យមើលសំណុំរឿង។ សំណើនេះបានផ្អែកលើមូលដ្ឋាននៃការអះអាងអំពីការផ្លាស់ប្តូរកាលៈទេសៈ ដូចជាថា [redacted] និង [redacted] បានដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីនៅក្នុងសំណុំរឿង ០០៣ និង ០០៤ [14]។

14. នៅថ្ងៃទី ៣០ ខែ មេសា ឆ្នាំ ២០១១ កិច្ចសន្យាការងារប្រឹក្សារបស់លោក គង់ សំអុន បានអស់សុពលភាព [15]។

15. នៅថ្ងៃទី ១៩ ខែ ឧសភា ឆ្នាំ ២០១១ សហចៅក្រមស៊ើបអង្កេត បានចេញ *ដីកាសម្រេចស្តីអំពីសំណើពិនិត្យឡើងវិញនូវដីកាសម្រេចលើសំណើរបស់មេធាវីការពារក្តីសុំពិនិត្យមើលសំណុំរឿង ០០៣ និង ០០៤ ចុះថ្ងៃទី ០៥ ខែ មេសា ឆ្នាំ ២០១១* ក្នុងនោះ សហចៅក្រមស៊ើបអង្កេតបានច្រានចោលសំណើចុះថ្ងៃទី ២៩ ខែ មេសា ឆ្នាំ ២០១១។ នៅក្នុងដីកាសម្រេចនេះ សហចៅក្រមស៊ើបអង្កេត បានបញ្ជាក់ថា សំណើដែលបានដាក់ដោយ [redacted] និង [redacted] មិនបានធ្វើឱ្យមានការផ្លាស់ប្តូរកាលៈទេសៈទេ ហើយក៏មានគ្មានភាពអយុត្តិធម៌ត្រូវបានបង្កឡើងដល់ជនសង្ស័យដែរ (ពីព្រោះថា ពាក្យសុំតាំងខ្លួនជាដើមបណ្តឹង

---

[14] សំណុំរឿង ០០៤ ឯកសារ D4/2 *សំណើពិនិត្យឡើងវិញនូវដីកាសម្រេចលើសំណើរបស់មេធាវីការពារក្តី សុំពិនិត្យមើលសំណុំរឿងលេខ ០០៣ និង លេខ ០០៤ ចុះថ្ងៃទី ៥ ខែ មេសា ឆ្នាំ ២០១១* ចុះថ្ងៃទី ២៩ ខែ មេសា ឆ្នាំ ២០១១ កថាខណ្ឌ ១១។

[15] សំណុំរឿង ០០៤ ឯកសារ D103/1 *ការជូនដំណឹងអំពីការលុបចោលការចាត់តាំងលោក គង់ សំអុន-សំណុំរឿង ០០៣ និង ០០៤* ចុះថ្ងៃទី ២៤ ខែ តុលា ឆ្នាំ ២០១១។

រដ្ឋប្បវេណីទាំងពីរត្រូវបានច្រានចោល ហើយគ្មានអ្នកពាក្យសុំណាម្នាក់ក្នុងចំណោមនេះ បានទទួលការអនុញ្ញាតចូលពិនិត្យមើលសំណុំរឿងដែរ) [16] ។

16. នៅថ្ងៃទី ២៤ ខែ កុម្ភៈ ឆ្នាំ ២០១២ សហចៅក្រមស៊ើបអង្កេតអន្តរជាតិបម្រុង (“ស.ច.ស.អ.ប ”) បានចេញសេចក្តីសម្រេចស្តីពី*ការជូនដំណឹងអំពីសិទ្ធិរបស់ជនសង្ស័យ* (“ការជូនដំណឹងជាលាយលក្ខណ៍អក្សរ”) ក្នុងនោះគាត់បានជូនដំណឹងដល់ [redacted] (“ជនសង្ស័យ”) ជាជនសង្ស័យម្នាក់ក្នុងចំណោមជនសង្ស័យនៅក្នុងសំណុំរឿង ០០៤ ថា “លោកត្រូវបានជាប់ឈ្មោះថាជាជនសង្ស័យម្នាក់នៅក្នុងកិច្ចស៊ើបសួរកំពុងបន្តដំណើរការ ដោយយោងតាមដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួររបស់សហព្រះរាជអាជ្ញា ចុះថ្ងៃទី ២០ ខែ វិច្ឆិកា ឆ្នាំ ២០០៨ និងដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរបន្ថែម ចុះថ្ងៃទី ១៨ ខែ កក្កដា ឆ្នាំ ២០១១”[១៧] ។ ជនសង្ស័យក៏ត្រូវបានជូនដំណឹងអំពីបទចោទប្រកាន់ប្រឆាំងនឹងគាត់ ផងដែរ។ ត្រង់ចំណុចនេះ ស.ច.ស.អ.ប បានបញ្ជាក់ថា “ការចោទប្រកាន់ទាំងនេះគឺផ្អែកលើមូលដ្ឋានទាំងអង្គហេតុ ដែលត្រូវបានចោទប្រកាន់ដោយសហព្រះរាជអាជ្ញា និងអង្គហេតុដែលត្រូវបានរកឃើញនៅក្នុងអំឡុងពេលនៃកិច្ចស៊ើបសួរ”[១៨]។

17. បន្ថែមពីលើនេះទៀត ស.ច.ស.អ.ប បានជូនដំណឹងជនសង្ស័យ ថា៖

> *“ដោយអនុលោមតាមវិធានផ្ទៃក្នុងរបស់អ.វ.ត.ក លោកត្រូវចាត់ទុកថាគ្មានទោសដរាបណាពិរុទ្ធភាពរបស់លោក មិនទាន់ត្រូវបានរកឃើញ ហើយយើងនៅតែអាចរង់ចាំស្តាប់ចម្លើយភស្តុតាងពីលោក ទាក់ទងនឹងការចោទប្រកាន់ទាំងនេះប្រសិនបើលោកមានបំណងផ្តល់ភស្តុតាងបែបនេះ”* ហើយ “ដោយអនុលោមតាមវិធានផ្ទៃក្នុងរបស់ អ.វ.ត.ក *[វិធាន ២១(១)(ឃ)] សិទ្ធិ និងការធានានៅក្នុងកិច្ចដំណើរការ*

---

[16]សំណុំរឿង ០០៤ ឯកសារ D4/2/1 *ដីកាសម្រេចស្តីអំពីសំណើពិនិត្យឡើងវិញនូវដីកាសម្រេចលើសំណើរបស់មេធាវីការពារក្តីសុំពិនិត្យមើលសំណុំរឿង ០០៣ និង ០០៤ ចុះថ្ងៃទី ០៥ ខែ មេសា ឆ្នាំ ២០១១* ចុះថ្ងៃទី ១៩ ខែ ឧសភា ឆ្នាំ ២០១១។

[១៧]សំណុំរឿង ០០៤ ឯកសារ D110 *ការជូនដំណឹងអំពីសិទ្ធិរបស់ជនសង្ស័យ[វិធាន ២១(១)(ឃ)]* ចុះថ្ងៃទី ២៤ ខែ កុម្ភៈ ឆ្នាំ ២០១២ ។

[១៨]ដូចចុងទំព័រខាងលើ កថាខណ្ឌ ២ ។

00942425



*នីតិវិធីក្នុងឋានៈជាជនសង្ស័យ រួមមានសិទ្ធិមានមេធាវីការពារខ្លួនតាមការជ្រើសរើសរបស់ខ្លួន សិទ្ធិមានលទ្ធភាពទទួលបានឯកសារសំណុំរឿង(អនុវត្តស្រដៀងគ្នាតាមវិធាន ៥៥(៦) វិធាន ៥៥(១)*[19] *និងវិធាន ៥៨ លើកលែងតែបញ្ញត្តិនៃវិធាន ៥៨(៦) នៃវិធានផ្ទៃក្នុងរបស់ អ.វ.ត.ក) និងសិទ្ធិនៅស្ងៀមមិនឆ្លើយតបនៅគ្រប់ដំណាក់កាលទាំងអស់នៃកិច្ចដំណើរការនីតិវិធី'* [២០]។

18. នៅថ្ងៃទី ២៩ ខែ កុម្ភៈ ឆ្នាំ ២០១២ [21] ស.ច.ស.អ.ប បានជូនដំណឹងអំពីព័ត៌មានខាងលើនេះប្រាប់ជនសង្ស័យដោយផ្ទាល់មាត់ ("ការជូនដំណឹងដោយផ្ទាល់មាត់") [22] ។

19. នៅថ្ងៃទី ៣១ ខែ មីនា ឆ្នាំ ២០១២ ជនសង្ស័យ បានផ្ញើលិខិតមួយជូនទៅ សហចៅក្រមស៊ើបអង្កេត ដោយជម្រាបថា គាត់បានជួបសហមេធាវីរបស់គាត់ ឈ្មោះ ម៉ុម លុជ្ស និង Richard Rogers ហើយគាត់ចង់ប្រើសិទ្ធិរបស់គាត់នៅស្ងៀមមិនឆ្លើយតបនឹងការសួររហូតដល់មានការជូនដំណឹងបន្ថែមទៀត [23]។

---

[19] សូមកត់សម្គាល់ថា ជាភាសាបារាំង សេចក្តីសម្រេចស្តីពី*ការជូនដំណឹងអំពីសិទ្ធិរបស់ជនសង្ស័យ*(ឯកសារ 004-D110) សំដៅលើវិធាន ៥៥(១១) ខណៈដែល ភាសាអង់គ្លេស និងខ្មែរ សំដៅលើវិធាន ៥៥(១)។

[២០] សំណុំរឿង ០០៤ ឯកសារ D110 *ការជូនដំណឹងអំពីសិទ្ធិរបស់ជនសង្ស័យ[វិធាន ២១(១)(ឃ)]* ចុះថ្ងៃទី ២៤ ខែ កុម្ភៈ ឆ្នាំ ២០១២ កថាខណ្ឌ ៣ និង ៤។

[21] នៅក្នុងលិខិតដែល ស.ច.ស.អ.ប បានផ្ញើទៅអង្គភាពគាំពារការពារក្តី នៅថ្ងៃទី ៦ ខែ មីនា ឆ្នាំ ២០១២ កាលបរិច្ឆេទនៃការជូនដំណឹងផ្ទាល់មាត់ គឺចុះថ្ងៃទី ២៩ ខែ មីនា ឆ្នាំ ២០១២។ ទោះបីយ៉ាងណា ដោយយល់ឃើញថា លិខិតនេះចុះថ្ងៃទី ៦ ខែ មីនា ឆ្នាំ ២០១២ ហើយការជូនដំណឹងដូចគ្នានេះទៅជនសង្ស័យផ្សេងទៀតបានធ្វើឡើងនៅថ្ងៃទី ២៨ ខែ កុម្ភៈ ឆ្នាំ ២០១២ ស.ច.ស.អ យល់ឃើញថា ការចុះកាលបរិច្ឆេទថ្ងៃទី ២៩ ខែ មីនា ឆ្នាំ ២០១២ គឺមានការភាន់ច្រឡំ ហើយនឹងពិចារណាថាការជូនដំណឹងនោះត្រូវបានធ្វើឡើងនៅថ្ងៃទី ២៩ ខែ កុម្ភៈ ឆ្នាំ ២០១២។.

[22] សំណុំរឿង ០០៤ ឯកសារ D111 *លិខិតជូនទៅអង្គភាពគាំពារការពារក្តី ស្តីពីការជូនដំណឹងអំពីសិទ្ធិរបស់ជនសង្ស័យ [វិធាន ២១(១)(ឃ)]* ចុះថ្ងៃទី ៦ ខែ មីនា ឆ្នាំ ២០១២ កថាខណ្ឌ ៤។

[23] សំណុំរឿង ០០៤ ឯកសារ D111/3.1 *លិខិត* [redacted] ចុះថ្ងៃទី ៣១ ខែ មីនា ឆ្នាំ ២០១២។ សម្រាប់ប្រវត្តិលម្អិតអំពីការតែងតាំងលោក ម៉ុំ លុជ្ស និង លោក Richard Rogers ជាមេធាវីជនសង្ស័យ *សូមមើល* សំណុំរឿង ០០៤ ឯកសារ D122/6 *ដីកាសម្រេចលើញត្តិ និងសារណាបន្ថែមស្តីពីសិទ្ធិរបស់ជនសង្ស័យក្នុងការមានមេធាវី* ចុះថ្ងៃទី ១៧ ខែ ឧសភា ឆ្នាំ ២០១៣ (ដីកាសម្រេចស្តីពីសិទ្ធិក្នុងការមានមេធាវី) កថាខណ្ឌ ១៤-៤៣។ លោក Richard Rogers ត្រូវបាន ស.ច.ស.អ.ប ទទួលស្គាល់ជាផ្លូវការជាមេធាវីជនសង្ស័យ នៅថ្ងៃទី ៣ ខែ ឧសភា ឆ្នាំ ២០១២។ ទោះបីយ៉ាងណា

20. នៅថ្ងៃទី ៥ ខែ តុលា ឆ្នាំ ២០១២ អ.គ.ក បានតែងតាំងលោក Göran Sluiter ជាសហមេធាវីបរទេសសម្រាប់ជនសង្ស័យ [24]។

21. នៅថ្ងៃទី ២២ ខែ តុលា ឆ្នាំ ២០១២ ក្រុមការពារក្តីជនសង្ស័យ បានដាក់លិខិតមួយជូនទៅសហចៅក្រមស៊ើបអង្កេត ក្នុងនោះក្រុមការពារក្តីបានធ្វើការស្នើសុំដូចជា ស្នើសុំឱ្យ"*សហចៅក្រមស៊ើបអង្កេត ធានាថា ជនសង្ស័យនៅចំពោះមុខ អ.វ.ត.ក ទទួលបានសិទ្ធិទាំងអស់របស់ខ្លួនក្នុងការទទួលបានការជំនុំជម្រះក្តីប្រកបដោយយុត្តិធម៌ ហើយសិទ្ធិទាំងនេះមិនត្រូវមានត្រឹមតែទ្រឹស្តី និងបំភ័ន្តឡើយ ប៉ុន្តែត្រូវមានពិតប្រាកដ និងប្រកបដោយប្រសិទ្ធភាព*" [២៥]។

22. នៅថ្ងៃទី ១៤ ខែ ធ្នូ ឆ្នាំ ២០១២ ក្រុមការពារក្តីជនសង្ស័យ បានដាក់*សំណើជាបន្ទាន់សុំដីកាអនុញ្ញាតឱ្យចូលពិនិត្យមើលសំណុំរឿង* ("សំណើបន្ទាន់") ដោយស្នើសុំសហចៅក្រមស៊ើបអង្កេត ឱ្យបង្គាប់ ការិយាល័យរដ្ឋបាល ផ្តល់ជូនជនសង្ស័យនូវការអនុញ្ញាតចូលពិនិត្យមើលសំណុំរឿងស៊ើបអង្កេតទាំងអស់ពាក់ព័ន្ធនឹងកិច្ចដំណើរការនីតិវិធីប្រឆាំងនឹងគាត់ ដោយក្នុងសំណើបន្ទាន់នេះ ជនសង្ស័យត្រូវបានចាត់ទុកថាជា"ជនត្រូវចោទ" [២៦]។

23. នៅថ្ងៃទី ២០ ខែ ធ្នូ ឆ្នាំ ២០១២ ក្រុមការពារក្តីជនសង្ស័យ បានដាក់លិខិតមួយបន្ថែមទៀត ក្នុងនោះ ក្រុមការពារក្តីបានកំណត់ថាជនសង្ស័យគឺជា "ជនត្រូវចោទនៅចំពោះមុខ អ.វ.ត.ក" [27]

---

ក្រោយមក ការតែងតាំងរបស់គាត់ត្រូវបានលុបចោលនៅថ្ងៃទី ១៧ ខែ ឧសភា ឆ្នាំ ២០១៣ *សូមមើល* ដីកាសម្រេចស្តីពីសិទ្ធិក្នុងការមានមេធាវី កថាខណ្ឌ ១១០។

[24] សំណុំរឿង 004 ឯកសារ D111/8 *លិខិតរបស់អង្គភាពគាំពារការពារក្តី ការចាត់តាំងមេធាវីបរទេសតំណាង* [redacted] ចុះថ្ងៃទី ៥ ខែ តុលា ឆ្នាំ ២០១២។

[២៥] សំណុំរឿង 004 ឯកសារ D122/2.1.41 *លិខិតរបស់ក្រុមការពារក្តីជនសង្ស័យ* ចុះថ្ងៃទី ២២ ខែ តុលា ឆ្នាំ២០១២ កថាខណ្ឌ ១១ ។

[២៦] សំណុំរឿង 004 ឯកសារ D121 *សំណើជាបន្ទាន់សុំដីកាអនុញ្ញាតឱ្យចូលពិនិត្យមើលសំណុំរឿង* ចុះថ្ងៃទី ១៤ ខែ ធ្នូ ឆ្នាំ ២០១៣។

[27] សំណុំរឿង004 ឯកសារ D121/1 *សិទ្ធិ* [redacted] *ក្នុងការទទួលបានព័ត៌មានស្តីពីប្រភេទ និងមូលហេតុនៃការចោទប្រកាន់មកលើរូបគាត់ និងសិទ្ធិក្នុងការទទួលបានសម្ភារៈរូបវន្តគ្រប់គ្រាន់សម្រាប់ត្រៀមរៀបចំការពារក្តីរបស់ខ្លួន* ចុះថ្ងៃទី ២០ ខែ ធ្នូ ឆ្នាំ២០១២ កថាខណ្ឌ ៧។

ហើយក្រុមការពារក្តី ក៏បានបង្ហាញសេចក្តីព្រួយបារម្ភលើការរំលោភបំពានជាបន្តបន្ទាប់ទៅលើសិទ្ធិរបស់ជនសង្ស័យ។ ក្រុមការពារក្តីជនសង្ស័យ បានស្នើសុំបញ្ចូលលិខិតនេះបន្ថែមពីលើសំណើបន្ទាន់ (“លិខិតបន្ថែម”)”[២៨]។

24. នៅថ្ងៃទី ១៥ ខែ កុម្ភៈ ឆ្នាំ ២០១៣ ក្រុមការពារក្តីជនសង្ស័យ បានដាក់ជូនអង្គបុរេជំនុំជម្រះនូវ *បណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងការបដិសេធតាមការសន្មតលើសំណើបន្ទាន់សុំចេញដីកាសម្រេចឱ្យបើកមើលសំណុំរឿង*(“បណ្តឹងឧទ្ធរណ៍”) ក្នុងនោះក្រុមការពារក្តី បានលើកឡើងថា ការខកខានរបស់សហចៅក្រមស៊ើបអង្កេតមិន“...អនុញ្ញាតឱ្យជនត្រូវចោទបើកមើលសំណុំរឿងទោះជាជនត្រូវចោទបានស្នើសុំដដែលៗយ៉ាងណាក៏ដោយ [...គឺ]បានបដិសេធគាត់មិនឱ្យមានសិទ្ធិដើរតួនាទីយ៉ាងសកម្មនៅក្នុងដំណាក់កាលស៊ើបសួរនៃកិច្ចដំណើរការនីតិវិធីនៅចំពោះមុខ អ.វ.ត.ក...” ដូច្នេះមិនឱ្យតម្លៃដល់សិទ្ធិដែលបានធានាដល់រូបគាត់ក្នុងនាមជា “ជនត្រូវចោទ” [29]។ ដោយផ្អែកលើមូលដ្ឋាននេះ ក្រុមការពារក្តីជនសង្ស័យ បានស្នើ អង្គបុរេជំនុំជម្រះ សុំអនុញ្ញាតតាមសំណើរបស់ជនសង្ស័យដូចបានស្នើនៅក្នុងសំណើបន្ទាន់ [30]។

25. នៅថ្ងៃទី ២៦ ខែ កុម្ភៈ ឆ្នាំ ២០១៣ សហចៅក្រមស៊ើបអង្កេតអន្តរជាតិ (“ស.ច.ស.អ”) បានដាក់ *កំណត់សម្គាល់បញ្ជូនបន្តបណ្តឹងឧទ្ធរណ៍ទៅអង្គបុរេជំនុំជម្រះ* ដោយបញ្ជាក់លម្អិតអំពីសកម្មភាពដែលគាត់បានអនុវត្តចាប់តាំងពីមកដល់ អ.វ.ត.ក ហើយ បានបញ្ជាក់ថា គាត់យល់ដឹងពីលក្ខខណ្ឌតម្រូវក្នុងការឆ្លើយតបទៅនឹងសំណើផ្សេងៗ “ឱ្យបានឆាប់បំផុតតាមដែលអាចធ្វើទៅបាន ហើយនៅគ្រប់ករណីទាំងអស់ត្រូវចេញដីកានេះឱ្យបានមុនពេលបញ្ចប់កិច្ចស៊ើបសួរ” ប៉ុន្តែគាត់បានបញ្ជាក់ថា ដំបូង គាត់ត្រូវតែដោះស្រាយបញ្ហាបឋម និងសំខាន់

---

[២៨] សំណុំរឿង០០៤ ឯកសារ D121/1 *សិទ្ធិ[redacted]ក្នុងការទទួលបានព័ត៌មានស្តីពីប្រភេទ និងមូលហេតុនៃការចោទប្រកាន់មកលើរូបគាត់ និងសិទ្ធិក្នុងការទទួលបានសម្ភារៈរូបវ័ន្តគ្រប់គ្រាន់សម្រាប់ត្រៀមរៀបចំការពារក្តីរបស់ខ្លួន* ចុះថ្ងៃទី ២០ ខែ ធ្នូ ឆ្នាំ២០១២ កថាខណ្ឌ ៩។

[29] សំណុំរឿង០០៤ ឯកសារ D121/2/1 *បណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងការបដិសេធតាមការសន្មតលើសំណើបន្ទាន់សុំចេញដីកាសម្រេចឱ្យបើកមើលសំណុំរឿង* ចុះថ្ងៃទី ១៥ ខែ កុម្ភៈ ឆ្នាំ ២០១៣ កថាខណ្ឌ ៣។

[30] សំណុំរឿង០០៤ ឯកសារ D121/2/1 *បណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងការបដិសេធតាមការសន្មតលើសំណើបន្ទាន់សុំចេញដីកាសម្រេចឱ្យបើកមើលសំណុំរឿង* ចុះថ្ងៃទី ១៥ ខែ កុម្ភៈ ឆ្នាំ ២០១៣ កថាខណ្ឌ ៩។

ផ្សេងៗ ដែលជាលក្ខខណ្ឌចាំបាច់សម្រាប់ចេញសេចក្ដីសម្រេចណាមួយទៅលើការអនុញ្ញាតចូលពិនិត្យមើលសំណុំរឿង [31]។

26. នៅថ្ងៃទី ១២ ខែ មីនា ឆ្នាំ ២០១៣ ក្រុមការពារក្ដីជនសង្ស័យ បានផ្ញើលិខិតមួយជូនទៅ សហចៅក្រមស៊ើបអង្កេត ដោយស្នើសុំសិទ្ធិ *"ចូលរួមនៅក្នុងដំណើរការនីតិវិធីស៊ើបអង្កេត ដែលបាន និងកំពុងធ្វើទៅលើសំណុំរឿង ០០៤"* ("លិខិតចុះថ្ងៃទី ១២ ខែ មីនា ឆ្នាំ ២០១៣" ) [32]។

27. នៅថ្ងៃទី ៩ ខែ មេសា ឆ្នាំ ២០១៣ ដោយផ្អែកលើមូលដ្ឋាននៃព័ត៌មានដែលសហចៅក្រមស៊ើបអង្កេត បានផ្ដល់នៅក្នុង*កំណត់សម្គាល់បញ្ជូនបន្តបណ្ដឹងឧទ្ធរណ៍ទៅអង្គបុរេជំនុំជម្រះ* ក្រុមការពារក្ដីជនសង្ស័យ បានដកបណ្ដឹងឧទ្ធរណ៍វិញ [33]។

28. នៅថ្ងៃទី ១៧ ខែ មិថុនា ឆ្នាំ ២០១៣ ក្រុមការពារក្ដីជនសង្ស័យ [34] បានផ្ញើលិខិតមួយ ("លិខិតចុះថ្ងៃទី១៧ ខែ មិថុនា ឆ្នាំ ២០១៣")ជូនទៅសហចៅក្រមស៊ើបអង្កេត ក្នុងនោះក្រុមការពារក្ដីបានរំឭកថា នៅថ្ងៃទី ១ ខែ មេសា ឆ្នាំ ២០១៣ ស.ច.ស.អ បានអនុញ្ញាតឱ្យមេធាវីដើមបណ្ដឹងរដ្ឋប្បវេណី ចូលពិនិត្យមើលសំណុំរឿង បន្ទាប់មក ក្រុមការពារក្ដី បានបញ្ជាក់ថា

---

[31] សំណុំរឿង០០៤ ឯកសារ D121/2 *កំណត់សម្គាល់របស់សហចៅក្រមស៊ើបអង្កេតអន្តរជាតិ បញ្ជូនបន្តបណ្ដឹងឧទ្ធរណ៍ទៅអង្គបុរេជំនុំជម្រះ* ចុះថ្ងៃទី ២៦ ខែ កុម្ភៈ ឆ្នាំ ២០១៣។

[32] សំណុំរឿង០០៤ ឯកសារD121/3 *លិខិតពីក្រុមការពារក្ដី ផ្ញើជូនសហចៅក្រមស៊ើបអង្កេតស្ដីពីចូលរួមនៅក្នុងការស៊ើបអង្កេត* ចុះថ្ងៃទី ១២ ខែ មីនា ឆ្នាំ ២០១៣ ("លិខិតចុះថ្ងៃទី ១២ ខែ មីនា ឆ្នាំ ២០១៣")។

[33] សំណុំរឿង០០៤ ឯកសារ D121/2/2 *ការជូនដំណឹងអំពីការដកបណ្ដឹងឧទ្ធរណ៍* ចុះថ្ងៃទី ៩ ខែ មេសា ឆ្នាំ ២០១៣ កថាខណ្ឌ ៥-៦។

[34] សំណើបន្ទាន់ លិខិតបន្ថែម បណ្ដឹងឧទ្ធរណ៍ លិខិតចុះថ្ងៃទី ១២ ខែ មីនា ឆ្នាំ ២០១៣ និងលិខិតដកពាក្យបណ្ដឹងឧទ្ធរណ៍ ត្រូវបានចុះហត្ថលេខាដោយលោក Richard Rogers លោក មុំ លុដ្ឋ និងលោក Göran Sluiter។ ទោះបីយ៉ាងណា នៅថ្ងៃទី ១៧ ខែ ឧសភា ឆ្នាំ ២០១៣ ស.ច.ស.អ បានលុបចោលការទទួលស្គាល់លោក Richard Rogers ជាមេធាវីបរទេសតំណាងជនសង្ស័យ។ លិខិតចុះថ្ងៃទី ១៧ ខែ មិថុនា ឆ្នាំ ២០១៣ ត្រូវបានចុះហត្ថលេខាដោយលោក មុំ លុដ្ឋ និងលោក Göran Sluiter តែប៉ុណ្ណោះ។

*"ច្បាស់ណាស់ថា មេធាវីដែលត្រូវបានទទួលស្គាល់ ត្រូវតែបានអនុញ្ញាតឱ្យចូលពិនិត្យសំណុំរឿង"* [35]។

## ខ. សារណា

29. នៅក្នុងសំណើបន្ទាន់ ក្រុមការពារក្តីជនសង្ស័យ បានស្នើ សហចៅក្រមស៊ើបអង្កេត ("ស.ច.ស") ឱ្យបង្គាប់ ការិយាល័យរដ្ឋបាល ផ្តល់ការអនុញ្ញាតចូលពិនិត្យមើលសំណុំរឿង ដល់ជនសង្ស័យ ដែលក្រុមការពារក្តី បានសំដៅថាជា "ជនត្រូវចោទ" [36] ។ នៅក្នុងការគាំទ្រសំណើរបស់ខ្លួន ក្រុមការពារក្តីជនសង្ស័យ បានបញ្ជាក់ថា ក្នុងនាមជា "ជនត្រូវចោទ" ជនសង្ស័យ មាន "សិទ្ធិនៅក្រោមវិធាន ៥៥(៦) និង វិធាន ៨៦ នៃវិធានផ្ទៃក្នុងរបស់ អ.វ.ត.ក ដើម្បីពិនិត្យមើលសំណុំរឿងនៅគ្រប់ដំណាក់កាលទាំងអស់នៃការស៊ើបសួរប្រឆាំងនឹងរូបគាត់"។ សំណើនេះក៏បានបញ្ជាក់ទៀតថា ក្នុងនាមជា "ជនត្រូវចោទ" ជនសង្ស័យ មានសិទ្ធិពិនិត្យមើលសំណុំរឿង ដោយផ្អែកលើមូលដ្ឋាននៃមាត្រា ១៤(៣)(ខ)នៃកតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ។ នៅក្នុងសារណារបស់ក្រុមការពារក្តីជនសង្ស័យ សិទ្ធិចូលពិនិត្យមើលសំណុំរឿងគឺជាផ្នែកមួយនៃសិទ្ធិទទួលបានមធ្យោបាយគ្រប់គ្រាន់ [37]។

30. ក្រុមការពារក្តីជនសង្ស័យ បានផ្តល់ទឡ្ហីករណ៍ថា ព័ត៌មានតែមួយគត់ដែលបានផ្តល់ទៅជនសង្ស័យអំពីការស៊ើបអង្កេតប្រឆាំងនឹងគាត់ គឺត្រឹមតែជាការជូនដំណឹងអំពីសិទ្ធិរបស់ជនសង្ស័យ ចេញនៅថ្ងៃទី ២៤ ខែ កុម្ភៈ ឆ្នាំ ២០១២ និងការជូនដំណឹងផ្ទាល់មាត់នៅថ្ងៃទី ២៩ ខែ កុម្ភៈ ឆ្នាំ ២០១៣ [38] ហើយព័ត៌មាននេះ "គ្រាន់តែទិដ្ឋភាពទូទៅស្រពិចស្រពិលទាក់ទងនឹងលក្ខណៈ និងបុព្វហេតុនៃការចោទប្រកាន់ប្រឆាំងរូបគាត់តែប៉ុណ្ណោះ"[39] ។

---

[35] សំណុំរឿង០០៤ ឯកសារ D122/7 *លិខិតជូនសហចៅក្រមស៊ើបអង្កេត និងសហព្រះរាជអាជ្ញា ទាក់ទងនឹងការខកខានរបស់សហចៅក្រមស៊ើបអង្កេត មិនអនុញ្ញាតឱ្យសហមេធាវីតំណាង* [redacted] *ចូលពិនិត្យមើលសំណុំរឿង* ចុះថ្ងៃទី ១៧ ខែ មិថុនា ឆ្នាំ ២០១៣ ទំព័រ ២។

[36] សំណើបន្ទាន់ កថាខណ្ឌ ១ និង ១៥។

[37] សំណើបន្ទាន់ កថាខណ្ឌ ១,៥ និង ៩។

[38] សំណើបន្ទាន់ កថាខណ្ឌ ៣។

[39] សំណើបន្ទាន់ កថាខណ្ឌ ៨។

31. បន្ថែមពីលើនេះទៀត ក្រុមការពារក្តីជនសង្ស័យ បានលើកឡើងថា ទោះបីជាការស៊ើបអង្កេតរក្សាការសម្ងាត់ក៏ដោយ ក៏ឈ្មោះរបស់ជនសង្ស័យត្រូវបានលើកឡើងដោយប្រព័ន្ធផ្សព្វផ្សាយជាតិ និងអន្តរជាតិ ទាក់ទងនឹងកិច្ចដំណើរការនីតិវិធីប្រឆាំងនឹងរូបគាត់ ហើយគាត់ត្រូវបានបុគ្គលិកនៃប្រព័ន្ធផ្សព្វផ្សាយទៅជួបជាច្រើនដង។ ក្រុមការពារក្តីជនសង្ស័យ បានផ្តល់ទឡ្ហីករណ៍ថែមទៀតថា "ខណៈដែល [ជនសង្ស័យ] ត្រូវបានគេសង្ស័យថាបានប្រព្រឹត្តបទល្មើសធ្ងន់ធ្ងរ ជនត្រូវចោទត្រូវបានគេបដិសេធនូវមធ្យោបាយចាំបាច់ក្នុងការរៀបចំការការពារក្តីរបស់គាត់"[40]។

32. ក្រុមការពារក្តីជនសង្ស័យ បានលើកឡើងថែមទៀតថា "រយៈពេល ៤ ឆ្នាំបានកន្លងផុតទៅ ហើយចាប់តាំងពីជនត្រូវចោទមានឈ្មោះក្នុងដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរលើកទី ៣" ហើយការខកខានជាបន្តបន្ទាប់មិនផ្តល់ឱ្យគាត់នូវការអនុញ្ញាតចូលពិនិត្យសំណុំរឿង គឺជាការរំលោភច្បាប់ស្តីពីការបង្កើត អ.វ.ត.ក និងបទដ្ឋានសិទ្ធិមនុស្សអន្តរជាតិផងដែរ [41]។

33. នៅក្នុងលិខិតបន្ថែម ក្រុមការពារក្តីជនសង្ស័យ បានបង្ហាញសេចក្តីព្រួយបារម្ភៈរបស់ខ្លួនស្តីពីការរំលោភបំពានជាបន្តបន្ទាប់ទៅលើសិទ្ធិរបស់កូនក្តី ក្នុងនាមជា "ជនត្រូវចោទនៅចំពោះមុខ អ.វ.ត.ក" [42] រួមមាន សិទ្ធិទទួលបានការជូនដំណឹងអំពីប្រភេទ និងមូលហេតុនៃការចោទប្រកាន់មកលើរូបគាត់ សិទ្ធិទទួលបានពេលវេលា និងសម្ភារៈគ្រប់គ្រាន់ដើម្បីត្រៀមរៀបចំកិច្ចការពារក្តីរបស់គាត់ និងសិទ្ធិចូលមើលសំណុំរឿង [43]។ ក្រុមការពារក្តីជនសង្ស័យ ក៏បានបង្ហាញសេចក្តីព្រួយបារម្ភៈថា ស.ច.ស កំពុងបន្តកិច្ចស៊ើបសួរទៅមុខ រួមមាន ការអញ្ជើញជនរងគ្រោះ ឱ្យដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី ប៉ុន្តែមិនបានខិតខំប្រឹងប្រែងគ្រប់គ្រាន់ដើម្បីជូនដំណឹង ជនសង្ស័យ អំពីការចោទប្រកាន់ និងការវិវត្តនៃកិច្ចដំណើរការនីតិវិធីប្រឆាំងនឹងរូបគាត់ [44]។ ចុងក្រោយបំផុត ក្រុមការពារក្តីជនសង្ស័យ បានបញ្ជាក់ម្តង

---

[40] សំណើបន្ទាន់ កថាខណ្ឌ ៨។

[41] សំណើបន្ទាន់ កថាខណ្ឌ ១៤។

[42] លិខិតបន្ថែម កថាខណ្ឌ ៧។

[43] លិខិតបន្ថែម កថាខណ្ឌ ១។

[44] លិខិតបន្ថែម កថាខណ្ឌ ៥។

ទៀតថា ជនសង្ស័យ មានអាយុ [redacted]ឆ្នាំ សុខភាពទ្រុឌទ្រោម ឈ្មោះគាត់ត្រូវបាន ចុះផ្សាយដោយប្រព័ន្ធផ្សព្វផ្សាយជាតិ និងអន្តរជាតិ ហើយគាត់ក៏ត្រូវបានបុគ្គលិកនៃប្រព័ន្ធ ផ្សព្វផ្សាយទៅជួបជាច្រើនដងផងដែរ[45]។ ក្រុមការពារក្តីជនសង្ស័យ ក៏បានស្នើសុំឱ្យផ្តល់នូវ *"ព័ត៌មានពេញលេញ ពាក់ព័ន្ធនឹងប្រភេទ និងមូលហេតុនៃការចោទប្រកាន់មកលើរូបគាត់ និងអនុញ្ញាតឱ្យគាត់អាចចូលមើលសំណុំរឿងស៊ើបអង្កេត ពាក់ព័ន្ធនឹងកិច្ចដំណើរការនីតិវិធីប្រឆាំងរូបគាត់បានផង"* [46]។

34. នៅក្នុងលិខិតចុះថ្ងៃទី ១២ ខែ មីនា ឆ្នាំ ២០១៣ ក្រុមការពារក្តីជនសង្ស័យ បានស្នើសុំចូលរួម នៅក្នុងដំណើរការនីតិវិធីស៊ើបអង្កេតដែលបាន និងកំពុងអនុវត្តនៅក្នុងសំណុំរឿង ០០៤។ ជាពិសេស ក្រុមការពារក្តីបានស្នើសុំជួបតទល់ផ្ទាល់ជាមួយនឹងសាក្សីទាំងអស់ដែលត្រូវបាន ស្តាប់ចម្លើយដោយ ស.ច.ស និងសុំអនុញ្ញាតឱ្យដាក់សំណួរសួរទៅកាន់សាក្សីទាំងនោះតាម រយៈ ស.ច.ស។ នៅក្នុងសំណើរបស់ក្រុមការពារក្តី ការចូលរួមនៅក្នុងការស៊ើបអង្កេត នឹង ជួយដល់ការស្វែងរកការពិត [47] ។

35. នៅក្នុងលិខិតចុះថ្ងៃទី ១៧ ខែ មិថុនា ឆ្នាំ ២០១៣ ក្រុមការពារក្តីជនសង្ស័យ បានផ្តល់ ទឡ្ហីករណ៍ថា ការខកខានមិនអនុញ្ញាតឱ្យជនសង្ស័យចូលពិនិត្យសំណុំរឿង គឺ *"មិនគ្រាន់តែខុសច្បាប់ប៉ុណ្ណោះតែ"* ប៉ុន្តែក៏ *"បញ្ជូនសារវំខានផងដែរ [...]អំពីឋានានុក្រមរបស់ភាគី ក្នុងនោះ សិទ្ធិរបស់ជនសង្ស័យត្រូវបានចាត់ទុកថាតូចជាងសិទ្ធិរបស់សហព្រះរាជអាជ្ញា និងដើមបណ្តឹងរដ្ឋប្បវេណី"* [48]។ ក្រុមការពារក្តីជនសង្ស័យ ពឹងផ្អែកលើ *សេចក្តីសម្រេចទទួល*

---

[45] លិខិតបន្ថែម កថាខណ្ឌ ៨។

[46] លិខិតបន្ថែម កថាខណ្ឌ ៩។

[47] សំណុំរឿង០០៤ ឯកសារ D121/3 *លិខិតពីក្រុមការពារក្តី ផ្ញើជូនសហចៅក្រមស៊ើបអង្កេតស្តីពីចូលរួមក្នុងការស៊ើបអង្កេត* ចុះថ្ងៃទី ១២ ខែ មីនា ឆ្នាំ ២០១៣ ("លិខិតចុះថ្ងៃទី ១២ ខែ មីនា ឆ្នាំ ២០១៣")។

[48] សំណុំរឿង០០៤ ឯកសារ D122/7 *លិខិតជូនសហចៅក្រមស៊ើបអង្កេត និងសហព្រះរាជអាជ្ញា ទាក់ទងនឹងការខកខានរបស់សហចៅក្រមស៊ើបអង្កេត មិនអនុញ្ញាតឱ្យសហមេធាវីតំណាង[redacted]ចូលពិនិត្យមើលសំណុំរឿង* ចុះថ្ងៃទី ១៧ ខែ មិថុនា ឆ្នាំ ២០១៣។

*ស្គាល់មេធាវី* ចេញថ្ងៃទី ១ ខែ មេសា ឆ្នាំ ២០១៣ [49] ហើយបញ្ជាក់ថា ដោយផ្អែកលើមូលដ្ឋាន នេះ *"ច្បាស់ណាស់ថា មេធាវីដែលត្រូវបានទទួលស្គាល់ ត្រូវតែបានអនុញ្ញាតឱ្យចូលពិនិត្យសំណុំរឿង"*។[50]

## គ. ច្បាប់ជាធរមាន

<u>មាត្រា ១២ នៃកិច្ចព្រមព្រៀងរវាងអង្គការសហប្រជាជាតិ និងរាជរដ្ឋាភិបាលកម្ពុជា</u>

[...]

អង្គជំនុំជម្រះវិសាមញ្ញ ត្រូវអនុវត្តយុត្តាធិការរបស់ខ្លួន សមស្របតាមបទដ្ឋានយុត្តិធម៌អន្តរជាតិ ភាពត្រឹមត្រូវ និងដំណើរការសមស្របនៃច្បាប់ ដូចដែលបានចែងក្នុងមាត្រា ១៤ និង ១៥ នៃអនុសញ្ញាអន្តរជាតិឆ្នាំ ១៩៦៦ ស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយដែលកម្ពុជាគឺជាភាគីហត្ថលេខីដែរ។

[...]

<u>មាត្រា ២៣ នៃច្បាប់ស្តីពីការបង្កើត អ.វ.ត.ក</u>

"រាល់ការស៊ើបអង្កេត [...] អនុវត្តតាមនីតិវិធីដែលនៅជាធរមាន។ ប្រសិនបើនីតិវិធីដែលមានស្រាប់ពុំបានចែងពីករណីពិសេសមួយ ឬ ប្រសិនបើមានភាពមិនច្បាស់លាស់ ក្នុងការបកស្រាយ ឬអនុវត្តនីតិវិធីនោះ ឬ ប្រសិនបើមានបញ្ហាទាក់ទងទៅនឹងភាពសមស្រប នៃនីតិវិធីទាំងនេះជាមួយបទដ្ឋានអន្តរជាតិ សហចៅក្រមស៊ើបអង្កេតអាចស្វែងរក ការណែនាំក្នុងបទដ្ឋាននីតិវិធីដែលបានបង្កើតឡើងក្នុងកម្រិតអន្តរជាតិ។"

<u>មាត្រា ១៤ នៃកតិកាសញ្ញាអន្តរជាតិឆ្នាំ ១៩៦៦ ស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ ចែងពីផ្នែកពាក់ព័ន្ធ ថា៖</u>

"[...]

---

[49] សំណុំរឿង០០៤ ឯកសារ D126 *សេចក្តីសម្រេចទទួលស្គាល់មេធាវីដើមបណ្តឹងរដ្ឋប្បវេណី* ចុះថ្ងៃទី ១ ខែ មេសា ឆ្នាំ ២០១៣។

[50] លិខិតចុះថ្ងៃទី ១៣ ខែ មិថុនា ឆ្នាំ ២០១៣ ទំព័រ ២។

៣. ក្នុងការសម្រេចសេចក្តីចោទប្រកាន់ពីបទព្រហ្មទណ្ឌណាមួយប្រឆាំងមកលើខ្លួន ជនគ្រប់រូបមានសិទ្ធិទទួលបានការធានាជាអប្បបរិមា ដោយស្មើភាពគ្នាយ៉ាងពេញលេញ។

[...]

(ខ) ត្រូវមានពេលវេលា និងសម្ភារៈរូបវ័ន្តគ្រប់គ្រាន់ សម្រាប់រៀបចំការពារខ្លួន និងឆ្លើយឆ្លងជាមួយនឹងមេធាវីដែលជ្រើសរើសដោយខ្លួនឯង។

[...]

វិធានផ្ទៃក្នុង ២១(១)(ឃ)របស់ អ.វ.ត.ក ចែងថា៖

"ជនណាដែលត្រូវបានសង្ស័យ ឬត្រូវបានចោទប្រកាន់ ត្រូវចាត់ទុកថាគ្មានទោស ដរាបណាពិរុទ្ធភាពរបស់គេមិនទាន់ត្រូវបានរកឃើញ។ ជនទាំងនេះមានសិទ្ធិទទួលដំណឹងអំពីបទល្មើសដែលចោទប្រកាន់ចំពោះខ្លួន និងមានមេធាវីការពារតាមការជ្រើសរើសរបស់ខ្លួន ហើយនិងនៅក្នុងគ្រប់ដំណាក់កាលទាំងអស់នៃកិច្ចដំណើរការនីតិវិធី ត្រូវផ្តល់ព័ត៌មានដល់គេអំពីសិទ្ធិនៅស្ងៀមមិនឆ្លើយតប។"

<u>វិធានផ្ទៃក្នុង ៥៥ របស់ អ.វ.ត.ក ចែងពីផ្នែកពាក់ព័ន្ធថា៖</u>

[...]

សហចៅក្រមស៊ើបអង្កេត មានអំណាចបើកការស៊ើបសួរប្រឆាំងនឹងជនទាំងឡាយណា ដែលមាន ឈ្មោះក្នុងដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរ។ សហចៅក្រមស៊ើបអង្កេតអាចបើកកិច្ចស៊ើបសួរផងដែរ ចំពោះបុគ្គលគ្រប់រូបដែលមានតម្រុយច្បាស់លាស់ និងស៊ីសង្វាក់បញ្ជាក់ថាបុគ្គលនោះអាចជាអ្នកទទួលខុសត្រូវក្នុងការប្រព្រឹត្តបទឧក្រិដ្ឋដែលមានចែងក្នុងដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរ ឬដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរបន្ថែម ទោះបីជាបុគ្គលទាំងនោះមិនមានឈ្មោះក្នុងដីកាក៏ដោយ។ ក្នុងករណីចុងក្រោយនេះ សហចៅក្រមស៊ើបអង្កេតត្រូវសួរយោបល់សហព្រះរាជអាជ្ញាមុនពេលដាក់បុគ្គលនោះឲ្យស្ថិតនៅក្រោមការពិនិត្យ។

[...]

ក្រឡាបញ្ជីរបស់សហចៅក្រមស៊ើបអង្កេត ត្រូវរក្សាទុកសំណុំរឿង រួមទាំងកំណត់ហេតុ និងរបាយការណ៍នៃការស៊ើបសួរ។ សហព្រះរាជអាជ្ញា និងមេធាវីរបស់ភាគីទាំងអស់ មានសិទ្ធិ

គ្រប់ពេលវេលាក្នុងការពិនិត្យ និងថតចម្លងសំណុំរឿង ក្រោមការឃ្លាំមើលរបស់ក្រឡាបញ្ជីនៃការិយាល័យសហចៅក្រមស៊ើបអង្កេត ក្នុងពេលម៉ោងធ្វើការ និងគោរពទៅតាមបទបញ្ជារបស់អង្គជំនុំជម្រះវិសាមញ្ញ។

[...]

គ្រប់ពេលវេលានៃការស៊ើបសួរ សហព្រះរាជអាជ្ញា ជនត្រូវចោទ ឬដើមបណ្តឹងរដ្ឋប្បវេណីអាចស្នើសុំឱ្យសហចៅក្រមស៊ើបអង្កេតចេញដីកា ឬបំពេញកិច្ចស៊ើបសួរណាមួយដែលខ្លួនយល់ឃើញថាមាន ប្រយោជន៍ដល់ការស៊ើបសួរ។ ប្រសិនបើសហចៅក្រមស៊ើបអង្កេតមិនយល់ព្រម សហចៅក្រមស៊ើបអង្កេតត្រូវចេញដីកា បដិសេធឱ្យបានឆាប់បំផុតតាមដែលអាចធ្វើទៅបាន ហើយនៅគ្រប់ករណីទាំងអស់ត្រូវចេញដីកានេះឱ្យបានមុនពេលបញ្ចប់កិច្ចស៊ើបសួរ។ ដីកាបដិសេធនេះ ត្រូវមានសំអាងហេតុ ហើយត្រូវជូនដំណឹងដល់ភាគី។ ដីកាបដិសេធនេះបើកផ្លូវប្តឹងឧទ្ធរណ៍។

សហព្រះរាជអាជ្ញា និងមេធាវីរបស់ភាគីពាក់ព័ន្ធមានសិទ្ធិសុំមើលសំណុំរឿងច្បាប់ដើម ប៉ុន្តែត្រូវគោរពទៅតាមពេលវេលាកំណត់ ដើម្បីធានាដល់និរន្តរភាពនៃកិច្ចដំណើរការនីតិវិធី។”

<u>វិធានផ្ទៃក្នុង ៥៧ របស់ អ.វ.ត.ក ចែងពីផ្នែកពាក់ព័ន្ធថា៖</u>

នៅពេលជនត្រូវចោទចូលបង្ហាញខ្លួន ចំពោះមុខសហចៅក្រមស៊ើបអង្កេតជាលើកដំបូង សហចៅក្រមស៊ើបអង្កេតត្រូវកត់ត្រាទុកនូវអត្តសញ្ញាណរបស់ជននោះ និងប្រាប់ជននោះអំពីបទចោទប្រកាន់ និងអំពីសិទ្ធិមាន មេធាវី និងសិទ្ធិក្នុងការនៅស្ងៀមមិនឆ្លើយនឹងសំណួរ។ ជនត្រូវចោទមានសិទ្ធិពិគ្រោះជាមួយមេធាវីមុនពេលដែលខ្លួនត្រូវបានសួរចម្លើយ និងមានមេធាវីអមជាមួយនៅក្នុងពេលសួរចម្លើយ។ ប្រសិនបើជនត្រូវចោទយល់ ព្រមឆ្លើយ នោះសហចៅក្រមស៊ើបអង្កេត ត្រូវធ្វើការសួរចម្លើយនោះភ្លាម។ កំណត់ហេតុសួរចម្លើយត្រូវដាក់ចូលក្នុងសំណុំរឿង។

<u>វិធានផ្ទៃក្នុង ៨៦ របស់ អ.វ.ត.ក ចែងថា៖</u>

នៅគ្រប់ពេលវេលា សហព្រះរាជអាជ្ញា និងមេធាវីរបស់ភាគីទាំងអស់ ត្រូវមានសិទ្ធិពិនិត្យមើល និងថត ចម្លងសំណុំរឿង ដោយស្ថិតនៅក្រោមការត្រួតពិនិត្យរបស់ក្រឡាបញ្ជីនៃអង្គជំនុំជម្រះសាលាដំបូង នៅពេលម៉ោងធ្វើការ និងត្រូវគោរពទៅតាមលក្ខខណ្ឌតម្រូវសម្រាប់ដំណើរការល្អរបស់អង្គជំនុំជម្រះវិសាមញ្ញនៅក្នុងតុលាការកម្ពុជា។

<u>អំណាចមានជាប់រួចជាស្រេចក្នុងការពិចារណាឡើងវិញលើសេចក្តីសម្រេចមុនៗ</u>

ចៅក្រមមានអំណាចជាប់រួចជាស្រេចក្នុងការពិចារណាឡើងវិញលើសេចក្តីសម្រេចមុនណាមួយក្នុងករណីដែលមានការផ្លាស់ប្តូរកាលៈទេសៈ និងក្នុងករណីដែលសេចក្តីសម្រេចមុនមានការភ័ន្តច្រឡំ ឬបណ្តាលឱ្យមានភាពអយុត្តិធម៌[51]។

អំណាចនេះអាចអនុវត្តបានផងដែរក្នុងនៅក្នុងសេចក្តីសម្រេច *proprio motu* [52] ។

---

[51] តុលាការ ICTY *រដ្ឋអាជ្ញាតទល់នឹង Milosevic,* IT-02-54-T អង្គជំនុំជម្រះសាលដំបូង *សេចក្តីសម្រេចលើសំណើរបស់រដ្ឋអាជ្ញាសុំឱ្យធ្វើការពិចារណាឡើងវិញទាក់ទងនឹងភស្តុតាងរបស់សាក្សីការពារក្តីឈ្មោះ Mitar Balevic, Vladislav Jovanovic, Vukasin Andric និង Dobre Aleksovski និងសេចក្តីសម្រេច* proprio motu *ពិចារណាឡើងវិញលើការទទួលយកវត្ថុតាង 837 និង 838 ទាក់ទងនឹងភស្តុតាងរបស់សាក្សីការពារក្តីឈ្មោះ Barry Lituch* ថ្ងៃទី ១៧ ខែ ឧសភា ឆ្នាំ ២០០៥ កថាខណ្ឌ ៧-៨។ តុលាការ ICTY រដ្ឋអាជ្ញា តទល់នឹង *Galic,* IT-98-29-AR73 អង្គជំនុំជម្រះតុលាការឧទ្ធរណ៍ *សេចក្តីសម្រេចលើសំណើរបស់រដ្ឋអាជ្ញាសុំការអនុញ្ញាតប្តឹងឧទ្ធរណ៍* ថ្ងៃទី ១៤ ខែ ធ្នូ ឆ្នាំ ២០០១ កថាខណ្ឌ ១៣។ តុលាការ ICTY *រដ្ឋអាជ្ញាតទល់នឹង Mucic និងអ្នកផ្សេងទៀត* IT-96-21-A*bis*, អង្គជំនុំជម្រះតុលាការឧទ្ធរណ៍ *សាលដីកាលើបណ្តឹងឧទ្ធរណ៍អំពីការកាត់ទោស* ថ្ងៃទី ៨ ខែ មេសា ឆ្នាំ ២០០៣។ តុលាការ ICTY *រដ្ឋអាជ្ញាតទល់នឹង Milutinovic* និងអ្នកផ្សេងទៀត IT-05-87-T អង្គជំនុំជម្រះសាលាដំបូង *សេចក្តីសម្រេចលើសំណើរបស់រដ្ឋអាជ្ញាសុំឱ្យពិចារណាឡើងវិញ ទៅលើសេចក្តីសម្រេចលើសំណើរបស់រដ្ឋអាជ្ញាសុំឱ្យមានវិធានការការពារបន្ថែមទាក់ទងនឹងការជំនុំជម្រះសម្រាប់សាក្សី K56* ថ្ងៃទី ៩ ខែ វិច្ឆិកា ឆ្នាំ ២០០៦ កថាខណ្ឌ ២។

[52] សំណុំរឿង០០៤ ឯកសារ D14/1/2 *ដីកាសម្រេចព្យួរការអនុវត្ត "ដីកាសម្រេចស្តីពីសេចក្តីថ្លែងការណ៍ជាសាធារណៈរបស់សហព្រះរាជអាជ្ញាអន្តរជាតិ ទាក់ទងនឹងសំណុំរឿង ០០៣* ចុះថ្ងៃទី ១៣ ខែ មិថុនា ឆ្នាំ ២០១១ កថាខណ្ឌ ៤។ រឿងក្តី *Callixte Nzabonimana* តទល់នឹងរដ្ឋអាជ្ញា ឯកសារសំណុំរឿង Case Nos. ICTR-98-44D-AR7*bis,* ICTR-98-44D-AR7*bis*.2 *សេចក្តីសម្រេចលើបណ្តឹងឧទ្ធរណ៍បន្ទាន់របស់ Callixte Nzabonimana លើដីកាសម្រេចលុបចោលសេចក្តីសម្រេចចុះថ្ងៃទី ៤ ខែ មីនា ឆ្នាំ ២០១០ និងលើសំណើសុំប្តឹងឧទ្ធរណ៍ប្រឆាំងនឹងសេចក្តីសម្រេចរបស់ប្រធានចុះថ្ងៃទី ៥ ខែ ឧសភា ឆ្នាំ ២០១០* ថ្ងៃទី ២០ ខែ កញ្ញា ឆ្នាំ ២០១០ កថាខណ្ឌ ២៩។

## ឃ. វិភាគ

### I. សិទ្ធិពិនិត្យមើលសំណុំរឿង និងចូលរួមការស៊ើបអង្កេត

36. វិធានផ្ទៃក្នុង បែងចែងយ៉ាងច្បាស់រវាងជនសង្ស័យ និងជនត្រូវចោទ[53] ហើយផ្ដល់ជូនជនត្រូវចោទនូវសិទ្ធិកាន់តែទូលំទូលាយ [54] ។

37. សិទ្ធិចូលពិនិត្យសំណុំរឿង ត្រូវបានកំណត់ដោយវិធានផ្ទៃក្នុង ៥៥(៦), ៥៥(១១) និង ៨៦ ហើយសិទ្ធិនេះត្រូវរក្សាទុកផ្ដាច់មុខជូនសហព្រះរាជអាជ្ញា និង *"មេធាវីរបស់ភាគីទាំងអស់"* ដូចជា ជនត្រូវចោទ ជនជាប់ចោទ និងភាគីដើមបណ្ដឹងរដ្ឋប្បវេណី។ ជនសង្ស័យមិនមែនជាភាគីនៅក្នុងកិច្ចដំណើរការនីតិវិធីឡើយ [55]។ ស្រដៀងគ្នានេះដែរ អនុលោមតាមវិធានផ្ទៃក្នុង ៥៥(៨) និង ៦០ មានតែភាគីប៉ុណ្ណោះដែលមានសិទ្ធិចូលរួមការស៊ើបអង្កេត និងជួបផ្ទាល់តទល់គ្នាជាមួយនឹងសាក្សី។

38. សិទ្ធិពិនិត្យសំណុំរឿងក៏ត្រូវបានធានាដោយមាត្រា ១៤(៣)(ខ) នៃកតិកាសញ្ញាអន្តរជាតិស្ដីពីសិទ្ធិនយោបាយ និងសិទ្ធិពលរដ្ឋ ដែលអាចអនុវត្តបានចំពោះកិច្ចដំណើរការនីតិវិធីនៅ អ.វ.ត.ក និងជាផ្នែកមួយនៃសិទ្ធិទទួលបានមធ្យោបាយគ្រប់គ្រាន់[56]។ មាត្រា ១៤(៣)(ខ) ផ្ដល់សិទ្ធិនេះឲ្យទៅជនទាំងឡាយដែលត្រូវ"ចោទ"។ ការវិភាគទៅលើយុត្តិសាស្ត្រអន្តរជាតិរួមមានករណីយុត្តិសាស្ត្រដែលត្រូវបានដកស្រង់នៅក្នុងសំណើបន្ទាន់ គឺបញ្ជាក់ថា លក្ខណៈជាសារវន្តនៃសិទ្ធិពិនិត្យមើលសំណុំរឿង ត្រូវបានទទួលស្គាល់ ទាក់ទងនឹងជនទាំងឡាយដែល

---

[53] *សូមមើល* វិធាន ៥៥(៤) ដែលចែងថា "សហចៅក្រមស៊ើបអង្កេតមានអំណាចបើកការស៊ើបសួរប្រឆាំងនឹងជនទាំងឡាយណាដែលមានឈ្មោះក្នុងដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរ" និងវិធាន ៥៥(៥) ដែលចែងថា "[...] សហចៅក្រមស៊ើបអង្កេត អាច៖ ក-កោះហៅ និង សួរចម្លើយជនសង្ស័យ និងជនត្រូវចោទ[...]"។

[54] *សូមមើល* វិធានផ្ទៃក្នុង ៥៥(៦), ៦០ និង ៨៦។

[55] *សូមមើល* សទ្ទានុក្រមនៃវិធានផ្ទៃក្នុង ស្ដីពី "ភាគី"។

[56]គណៈកម្មាធិការសិទ្ធិមនុស្ស មតិយោបល់ទូទៅលេខ ៣២៖ *មាត្រា ១៤៖ សិទ្ធិស្មើភាពគ្នានៅចំពោះមុខតុលាការ និងសាលាក្ដី និងទទួលបានការជំនុំជម្រះដោយយុត្តិធម៌* ចុះថ្ងៃទី ២៣ ខែ សីហា ឆ្នាំ ២00៧ កថាខណ្ឌ ៣៣។

ត្រូវចោទប្រកាន់ ពីព្រោះថា ចាំបាច់បំផុតត្រូវដេញដោលភស្តុតាងដែលត្រូវបានប្រមូល ឬដាក់ជូនដើម្បីគាំទ្របទចោទប្រកាន់ទាំងនោះ [57]។

39. ដើម្បីសម្រេចលើសំណើដូចបានស្នើនៅក្នុងសំណើបន្ទាន់ និងលើលិខិតចុះថ្ងៃទី ១២ ខែ មីនា ឆ្នាំ ២០១៣ ស.ច.ស.អ នឹងចាំបាច់ត្រូវកំណត់ថាតើ ជនសង្ស័យមាន ឬក៏មិនមានឋានៈជា "ជនត្រូវចោទ"នៅក្នុងកិច្ចដំណើរការនីតិវិធីទាំងនេះ ដូចដែលក្រុមការពារក្តីជនសង្ស័យបានអះអាងនៅក្នុងសំណើបន្ទាន់។

## II. លក្ខខណ្ឌតម្រូវសំខាន់ និងផ្លូវការសម្រាប់ចោទជនសង្ស័យណាម្នាក់នៅក្នុងអំឡុងពេលស៊ើបអង្កេត

40. ការសម្រេចធ្វើការចោទប្រកាន់ គឺជាបុព្វសិទ្ធិមួយរបស់ ស.ច.ស។ អនុលោមតាមវិធានផ្ទៃក្នុង ៥៥(៤) ស.ច.ស មានអំណាចឆន្ទានុសិទ្ធិចោទជនសង្ស័យណាម្នាក់ដែលមានឈ្មោះនៅក្នុងដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរ ឬជនផ្សេងទៀតប្រសិនបើមាន "តម្រុយច្បាស់លាស់ និងស៊ីសង្វាក់"។ បទដ្ឋាននេះ ត្រូវបានអនុវត្តស៊ីសង្វាក់គ្នានៅក្នុងករណីផ្សេងទៀតដែលត្រូវបានស៊ើបអង្កេតដោយ ក.ស.ច.ស និងត្រូវបានលើករំឭកផងដែរនៅក្នុងសេចក្តីសម្រេចមុនៗនៅក្នុងសំណុំរឿង ០០៤ [58]។ នីតិវិធីផ្លូវការសម្រាប់ចោទជនសង្ស័យណាម្នាក់ ត្រូវបានចែងនៅក្នុងវិធានផ្ទៃក្នុង ៥៧។

41. នៅក្នុង*ដីកាសម្រេចលើសំណើរបស់សហព្រះរាជអាជ្ញាសុំឱ្យធ្វើការបំភ្លឺអំពីបទចោទ* ចេញនៅថ្ងៃទី ២០ ខែ វិច្ឆិកា ឆ្នាំ ២០០៩ នៅក្នុងសំណុំរឿង ០០២ ("ដីកាសម្រេចស្តីពីការបញ្ជាក់

---

[57] តុលាការ ECtHR៖ *រឿងក្តី Leas តទល់នឹង Estonia* ចុះថ្ងៃទី ៦ ខែ មិថុនា ឆ្នាំ ២០១២ កថាខណ្ឌ ៧៦-៨០ *រឿងក្តី Jespers តទល់នឹងប៊ែលហ្ស៊ិក* ថ្ងៃទី ១៤ ខែ ធ្នូ ឆ្នាំ ១៩៨១ កថាខណ្ឌ ៥៦-៥៧ *រឿងក្តី Öcalan តទល់នឹងទួគី* ថ្ងៃទី ១២ ខែ មីនា ឆ្នាំ ២០០៣ កថាខណ្ឌ ១៥៨-១៧០។ គណៈកម្មាធិការសិទ្ធិមនុស្ស ផ្សព្វផ្សាយលេខ 676/1996 *រឿងក្តី Yasseen និង Thomas តទល់នឹងសាធារណៈរដ្ឋ Guyana* ថ្ងៃទី ៧ ខែ ឧសភា ឆ្នាំ ១៩៩៨ កថាខណ្ឌ ៧.១០។

[58] *សូមមើល* សំណុំរឿង ០០២ ឯកសារ D198/1 *ដីកាសម្រេចលើសំណើរបស់សហព្រះរាជអាជ្ញាណសុំឱ្យធ្វើការ បំភ្លឺ [អំពីបទចោទ]* ចុះថ្ងៃទី ២០ ខែ វិច្ឆិកា ឆ្នាំ ២០០៩ កថាខណ្ឌ ១០។ សំណុំរឿង ០០២ ឯកសារ D275 *កំណត់ហេតុស្តាប់ចម្លើយជនត្រូវចោទ* ចុះថ្ងៃទី ១៥ ខែ ធ្នូ ឆ្នាំ ២០០៩ កថាខណ្ឌ ៤-៥។ សំណុំរឿង ០០២ ឯកសារ D282 *កំណត់ហេតុស្តាប់ចម្លើយជនត្រូវចោទ* ចុះថ្ងៃទី ២១ ខែ ធ្នូ ឆ្នាំ ២០០៩ កថាខណ្ឌ ៤-៥។ សំណុំរឿង ០០២ ឯកសារ 4/1 *ដីកាសម្រេចលើសំណើសុំមើលសំណុំរឿងលេខ ០០៣ និង ០០៤* ចុះថ្ងៃទី ៥ ខែ មេសា ឆ្នាំ ២០១១ កថាខណ្ឌ ២២។

00942438



បំភ្លឺ) ស.ច.ស បានផ្ដល់ការពន្យល់យ៉ាងច្បាស់អំពីវិធានដែលចែងពីដំណើរការនៃការចោទប្រកាន់។ ស.ច.ស បានរំឭកថា ចៅក្រមមាន "អំណាច" ប៉ុន្តែមិនមែនកាតព្វកិច្ចទេ ដើម្បីចោទជនណាម្នាក់។ ស.ច.ស ក៏បានរំឭកថា អំណាចធ្វើការចោទជនណាម្នាក់មានចែងនៅក្នុងវិធានផ្ទៃក្នុង ៥៥(៤) ដោយក្នុងវិធាននេះ ការចោទប្រកាន់ជាផ្លូវការអាចធ្វើឡើងតែក្នុងករណីដែល"មានតម្រុយច្បាស់លាស់ និងស៊ីសង្វាក់បញ្ជាក់ថា បុគ្គលនោះអាចជាអ្នកទទួលខុសត្រូវក្នុងការប្រព្រឹត្តបទឧក្រិដ្ឋដែលមានចែងក្នុងដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរ [...]" [59]។

42. នៅក្នុងដីកាសម្រេចស្តីពីការបញ្ជាក់បំភ្លឺ ស.ច.ស បានបន្ថែមថា [ក្នុងដំណាក់កាលដែលត្រូវចោទជនណាម្នាក់] "ក្នុងអំឡុងពេលនៃការដាក់ឲ្យឋិតក្រោមការពិនិត្យ ការជូនដំណឹងអំពីបទចោទប្រកាន់ ទាមទារឲ្យមានការបញ្ជាក់អំពីការកំណត់បទល្មើសនៃអង្គហេតុទាំងនោះ" [60]។ នៅចុងទំព័រមួយនៃប្រយោគនេះ ស.ច.ស បានបញ្ជាក់ថា "ការដាក់ឲ្យឋិតក្រោមការពិនិត្យ គឺជានីតិវិធីមួយដែលក្នុងនោះ បុគ្គលម្នាក់ត្រូវបានគេជូនដំណឹងអំពីចរិតឧក្រិដ្ឋកម្មសក្តានុពលនៃអង្គហេតុ ដែលជាកម្មវត្ថុនៃការស៊ើបសួរ។ ក្នុងន័យនេះ ត្រូវមានការជូនដំណឹងដល់បុគ្គលនោះអំពីអង្គហេតុ និងការកំណត់បទល្មើសដែលអាចមាននៅត្រឹមដំណាក់កាលនៃការស៊ើបសួរនេះ" [61]។ ក្រុមការពារក្ដីជនសង្ស័យ ដកស្រង់ចុងទំព័រនេះដាច់ដោយឡែកឆ្ងាយពីបរិបទនៃចុងទំព័រនេះ ដើម្បីកំណត់ពីដំណើរការនៃការចោទប្រកាន់[62]។ ទោះបីជាយ៉ាង ការជូនដំណឹងអំពីអង្គហេតុដែលត្រូវបានចោទ និងការកំណត់បទល្មើសនៃអង្គហេតុទាំងនោះ គឺច្បាស់ណាស់គ្រាន់តែផ្នែកមួយនៃដំណើរការនៃការចោទប្រកាន់ ដែលមានលក្ខណៈកាន់តែទូលំទូលាយ និងអាស្រ័យលើលក្ខខណ្ឌតម្រូវតឹងរឹងផ្សេងទៀតដូចបានពិនិត្យខាងលើ។

43. នៅក្នុងសំណើបន្ទាន់ ក្រុមការពារក្ដីជនសង្ស័យ ក៏ដកស្រង់សទ្ទានុក្រមនៃវិធានផ្ទៃក្នុង ដោយតាមសទ្ទានុក្រមនេះ "ជនត្រូវចោទ" សំដៅលើ "បុគ្គលណាម្នាក់ដែលត្រូវចោទប្រកាន់ចំពោះ

---

[59] សំណុំរឿង ០០២ ឯកសារ D198/1 *ដីកាសម្រេចលើសំណើរបស់សហព្រះរាជអាជ្ញាសុំឲ្យធ្វើការបំភ្លឺ [អំពីបទចោទ]* ចុះថ្ងៃទី ២០ ខែ វិច្ឆិកា ឆ្នាំ ២០០៩ កថាខណ្ឌ ១០។

[60] ដូចចុងទំព័រខាងលើ។

[61] ដូចចុងទំព័រខាងលើ ចុងទំព័រ ១០។

[62] សំណើបន្ទាន់ ចុងទំព័រ ១។

រឿងក្តីណាមួយ ក្នុងចន្លោះពេលពីមានដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួររហូតដល់ដីកាបញ្ជូនរឿងទៅជំនុំជម្រះ ឬដីកាលើកលែងចោទប្រកាន់" ។ និយមន័យនេះ សំដៅលើជន "ត្រូវចោទ" គឺមិនមែនជាករណីសម្រាប់ជនសង្ស័យដែលមិនទាន់ត្រូវបានចោទប្រកាន់ ហើយនិយមន័យនេះ គ្រាន់តែផ្តល់ក្របខ័ណ្ឌពេលវេលាដែលបុគ្គលម្នាក់អាចក្លាយជាជនត្រូវចោទតែប៉ុណ្ណោះ។

44. សរុបមក វិធានផ្ទៃក្នុងចែងពីលក្ខខណ្ឌតម្រូវតឹងរឹងសម្រាប់ចោទជនណាម្នាក់។ ដំបូង ចាំបាច់ត្រូវមានតម្រុយច្បាស់លាស់ និងស៊ីសង្វាក់បញ្ជាក់ថា ជនសង្ស័យម្នាក់អាចទទួលខុសត្រូវចំពោះបទឧក្រិដ្ឋដែលបានចោទដោយព្រះរាជអាជ្ញានៅក្នុងដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរបន្ថែម។ ទីពីរ ជនសង្ស័យត្រូវបានចោទដោយអនុវត្តតាមនីតិវិធីដូចមានចែងនៅក្នុងវិធានផ្ទៃក្នុង ៥៧។ គួរកត់សម្គាល់ថា យោងតាមយុត្តិសាស្ត្របារាំង ដីកាចោទប្រកាន់ដែលត្រូវបានធ្វើឡើងក្នុងករណីគ្មានបទដ្ឋានភស្តុតាងដែលតម្រូវឱ្យមានគឺត្រូវតែប្រកាសថាគ្មានសុពលភាព ។ ទោះបីជាយុត្តិសាស្ត្របារាំងនេះ មិនអាចអនុវត្តផ្ទាល់ ឬក៏មិនត្រូវអនុវត្តក៏ដោយ ក៏យុត្តិសាស្ត្រនេះអាចផ្តល់ការណែនាំដ៏មានប្រយោជន៍នៅក្នុងការបកស្រាយវិធានផ្ទៃក្នុងដែរ[63]។

## III. ការជូនដំណឹងអំពីសិទ្ធិរបស់ជនសង្ស័យ ចុះថ្ងៃទី ២៤ ខែ កុម្ភៈ ឆ្នាំ ២០១២

45. នៅថ្ងៃទី ២៤ ខែ កុម្ភៈ ឆ្នាំ ២០១២ ដោយមានការជូនដំណឹងជាលាយលក្ខណ៍អក្សរ ស.ច.ស.អ.ប Laurent Kasper-Ansermet បានជូនដំណឹងជនសង្ស័យអំពីការចោទប្រកាន់ប្រឆាំងនឹងគាត់ ហើយបានបន្ថែមថា "*ឋានៈជាជនសង្ស័យ រួមមាន សិទ្ធិមានមេធាវីការពារខ្លួនតាមការជ្រើសរើសរបស់ខ្លួន សិទ្ធិមានលទ្ធភាពទទួលបានឯកសារសំណុំរឿង (អនុវត្តស្របៀងគ្នាតាមវិធាន ៥៥(៦) វិធាន ៥៥(១) និងវិធាន ៥៨ លើកលែងតែបញ្ញត្តិនៃវិធាន*

---

[63] 1er oct. 2003, n° 03-82.909 : JurisData n° 2003-020541 ; Bull. crim. 2003, n° 177 : « *est tenue de prononcer l'annulation d'une mise en examen lorsqu'il a été procédé à celle-ci en l'absence d'indices graves et concordants rendant vraisemblable que la personne mise en cause ait pu participer, comme auteur ou complice, à la commission de l'infraction dont le juge d'instruction est saisi* ». បកប្រែជាភាសាអង់គ្លេសដោយស.ច.ស.អ៖ "[តុលាការជាន់ខ្ពស់] ត្រូវប្រកាសទុកជាមោឃៈលើសេចក្តីសម្រេចចោទប្រកាន់ជនណាម្នាក់នៅពេលដែលសេចក្តីសម្រេចនោះត្រូវបានធ្វើឡើងដោយគ្មានភស្តុតាងពិតប្រាកដ ឬច្បាស់លាស់ទំនងជាបញ្ជាក់ថាជននោះអាចបានចូលរួម ដោយផ្ទាល់ ឬជាអ្នកសមគំនិតក្នុងការប្រព្រឹត្តបទល្មើសដែលចៅក្រមបានទទួល"។

00942440



*៥៨(៦) នៃវិធានផ្ទៃក្នុងរបស់ អ.វ.ត.ក ) និងសិទ្ធិនៅស្ងៀមមិនឆ្លើយតបនៅគ្រប់ដំណាក់កាលទាំងអស់នៃកិច្ចដំណើរការនីតិវិធី"* [64]។ នៅថ្ងៃទី ២៩ ខែ កុម្ភៈ ឆ្នាំ ២០១២ ស.ច.ស.អ.ប បានជូនដំណឹងផ្ទាល់មាត់ប្រាប់ជនសង្ស័យ អំពីឋានៈរបស់គាត់ជា "ជនសង្ស័យ"នៅក្នុងការស៊ើបអង្កេត។ ជនសង្ស័យក៏ត្រូវបានជូនដំណឹងផងដែរអំពីសិទ្ធិរបស់ខ្លួនដែលត្រូវបានសន្មតថាគ្មានទោស សិទ្ធិផ្តល់ភស្តុតាងជូនទៅស.ច.ស សិទ្ធិមានតំណាងដោយមេធាវីតាមជម្រើសរបស់ខ្លួន សិទ្ធិចូលពិនិត្យមើលសំណុំរឿង និងសិទ្ធិនៅស្ងៀមមិនឆ្លើយតបនៅគ្រប់ដំណាក់កាលទាំងអស់នៃកិច្ចដំណើរការនីតិវិធី [65]។

46. ការជូនដំណឹងជាលាយលក្ខណ៍អក្សរ និងការជូនដំណឹងផ្ទាល់មាត់ សំដៅដូចគ្នាទៅលើជនសង្ស័យថា ជា "ជនសង្ស័យ"ម្នាក់ ហើយបានជូនដំណឹងថា គាត់មានសិទ្ធិទទួលបានសិទ្ធិដូចមានចែងនៅក្នុងវិធានផ្ទៃក្នុង ២១(១)(ឃ)។ ការជូនដំណឹងទាំងនេះ ក៏បានអនុញ្ញាតឲ្យគាត់ពិនិត្យមើលសំណុំរឿង ជាសិទ្ធិមួយដែលវិធានផ្ទៃក្នុងរក្សាទុកសម្រាប់ជនត្រូវចោទ និងភាគីផ្សេងទៀត។ ស.ច.ស.អ.ប បានបដិសេធយ៉ាងច្បាស់លាស់មិនផ្តល់ឲ្យជនសង្ស័យនូវសិទ្ធិដូចមានចែងនៅក្នុងវិធានផ្ទៃក្នុង ៥៨(៦) ជាវិធានដែលអនុញ្ញាតឲ្យជនត្រូវចោទ ចូលរួមក្នុងការស៊ើបអង្កេត។

47. ការចូលពិនិត្យមើលសំណុំរឿងត្រូវបានអនុញ្ញាត ដោយរំលោភលើវិធានផ្ទៃក្នុង ដោយគ្មាននីតិវិធីដំបូងដែលត្រូវចោទជនសង្ស័យជាផ្លូវការសិនដោយអនុលោមតាមវិធានផ្ទៃក្នុង ៥៧។ ស.ច.ស.អ.ប ក៏មិនបានសម្រេចថា មានតម្រុយច្បាស់លាស់ និងស៊ីសង្វាក់ប្រឆាំងនឹងជនសង្ស័យដែរ។ បច្ចុប្បន្ននេះ ស.ច.ស.អ មិនទាន់សម្រេចថា លក្ខខណ្ឌតម្រូវនេះត្រូវបានបំពេញឡើយ។

48. ប៉ុន្តែ សិទ្ធិរបស់ជនសង្ស័យត្រូវបានពង្រីក ដោយប្រើប្រាស់មូលដ្ឋានស្រដៀងគ្នានៃការអនុវត្តវិធានផ្ទៃក្នុង ៥៥(៦), ៥៥(១) និង ៥៨ ដែលអនុវត្តផ្តាច់មុខចំពោះជនត្រូវចោទ និងភាគីផ្សេងទៀត។ អង្គបុរេជំនុំជម្រះបានបញ្ជាក់យ៉ាងច្បាស់ថា ស.ច.ស ត្រូវបានតម្រូវឲ្យផ្តល់

---

[64] ការជូនដំណឹងជាលាយល័ក្ខអក្សរ កថាខណ្ឌ ៤។

[65] ការជូនដំណឹងផ្ទាល់មាត់ កថាខណ្ឌ ៤ ។

សំអាងហេតុសម្រាប់សេចក្ដីសម្រេចរបស់ខ្លួន ។ ទោះបីជាមានលក្ខខណ្ឌតម្រូវនេះក៏ដោយ ក៏ ស.ច.ស.អ.ប មិនបានផ្ដល់សំអាងហេតុដែលប្រើប្រាស់មូលដ្ឋានស្រដៀងគ្នានោះដែរ [66]។

49. ដោយអនុញ្ញាតឱ្យជនសង្ស័យចូលពិនិត្យមើលសំណុំរឿង ស.ច.ស.អ.ប បានផ្ដល់ជូនជនសង្ស័យនូវសិទ្ធិដែលជនសង្ស័យគ្មានសិទ្ធិទទួលបានអនុលោមវិធានផ្ទៃក្នុង។ បន្ថែមពីលើនេះទៀត ស.ច.ស.អ.ប បានធ្វើដូច្នេះ ដោយមិនបានផ្ដល់សំអាងហេតុគាំទ្រសេចក្ដីសម្រេចនោះទេ។ ចំណុចនេះបង្កើតឱ្យមានការរំលោភបំពានលើឆន្ទានុសិទ្ធិតុលាការ។ ដោយផ្អែកលើមូលដ្ឋាននេះ ស.ច.ស.អ បានពិចារណាឡើងវិញលើផ្នែកផ្សេងៗនៃការជូនដំណឹងជាលាយលក្ខណ៍អក្សរ និងការជូនដំណឹងផ្ទាល់មាត់ ដែលអនុញ្ញាតឱ្យជនសង្ស័យចូលពិនិត្យមើលសំណុំរឿង ហើយ ស.ច.ស.អ លុបចោលការជូនដំណឹងទាំងនោះ។

## IV.ថាតើ បច្ចុប្បន្ននេះមាន ឬក៏មិនមានកត្តាណាផ្សេងទៀតដែលធានាឱ្យមានការអនុញ្ញាតចូលពិនិត្យមើលសំណុំរឿង

50. នៅក្នុងសេចក្ដីសម្រេចមុនមួយលើសំណើស្នើសុំចូលពិនិត្យមើលសំណុំរឿង ដោយគ្មានការចោទប្រកាន់ជាផ្លូវការ ស.ច.ស បានពិចារណាថាតើ ជនសង្ស័យម្នាក់ត្រូវបាន ឬមិនត្រូវ "ប៉ះពាល់ជាក់លាក់ [យ៉ាងធ្ងន់ធ្ងរ] "ដោយសារការស៊ើបអង្កេត [67]។

51. ក្នុងការពិចារណាដូច្នេះ ស.ច.ស បានពឹងផ្អែកលើករណីយុត្តិសាស្ត្រនៃតុលាការសិទ្ធិមនុស្សអឺរ៉ុប ("ECtRH") ទាក់ទងនឹងការចោទប្រកាន់អំពីការរំលោភសិទ្ធិទទួលបានការជំនុំជម្រះក្នុងពេលវេលាសមហេតុផល ដូចមានចែងនៅក្នុងមាត្រា ៦(១)នៃអនុសញ្ញាអឺរ៉ុបស្ដីពីសិទ្ធិមនុស្ស ("ECHR")។

---

[66]ស្ដីពីកាតព្វកិច្ចរបស់ស.ច.ស ត្រូវផ្ដល់សេចក្ដីសម្រេចដោយមានសំអាងហេតុ *សូមមើល* សំណុំរឿង ០០២ ឯកសារ D427/5/10 សាលដីកាលើបណ្ដឹងឧទ្ធរណ៍របស់ អៀង សារី ប្រឆាំងនឹងការសម្រេចបន្តថិរវេលានៃការឃុំខ្លួនបណ្ដោះអាសន្ននៅក្នុងដីកាដំណោះស្រាយ ចុះថ្ងៃទី ២១ ខែ មករា ឆ្នាំ ២០១១ កថាខណ្ឌ ២៧។

[67]សំណុំរឿង ០០៤ ឯកសារ D4/1 *ដីកាសម្រេចលើសំណើសុំមើលសំណុំរឿងលេខ ០០៣ និង ០០៤* ចុះថ្ងៃទី ៥ ខែ មេសា ឆ្នាំ ២០១១ ("ដីកាសម្រេចចុះថ្ងៃទី ៥ ខែ មេសា ឆ្នាំ ២០១១") កថាខណ្ឌ ៣-៨ និង ១២-១៣។

52. យោងតាមយុត្តិសាស្ត្ររបស់តុលាការ ECtRH *"សម្រាប់គោលបំណងនៃមាត្រា ៦ §១ ការចោទប្រកាន់ផ្លូវការអាចត្រូវកំណត់និយមន័យថាជា ការជូនដំណឹងផ្លូវការទៅបុគ្គលម្នាក់ពីសំណាក់អាជ្ញាធរមានសមត្ថកិច្ចស្តីពីការចោទប្រកាន់ណាមួយដែលថា គាត់បានប្រព្រឹត្តបទឧក្រិដ្ឋ ហើយនេះគឺជានិយមន័យមួយដែលស្របទៅនឹងការតេស្តពិនិត្យថាតើ ស្ថានភាព [របស់ជនសង្ស័យ]ត្រូវបានប៉ះពាល់ធ្ងន់ធ្ងរឬអត់"* [68] ។ ស.ច.ស.អ កត់សម្គាល់ថា ការតេស្តពិនិត្យនេះ មិនត្រូវបានតុលាការ ECtRH ពិភាក្សានៅក្នុងបរិបទនៃការអនុវត្តដែលអនុញ្ញាតឱ្យចូលពិនិត្យមើលសំណុំរឿងឡើយ។ គួរកត់សម្គាល់ថា នៅពេលដែលទទួលបានពាក្យបណ្តឹងទាក់ទងនឹងការចោទប្រកាន់អំពីការលោភបំពានលើសិទ្ធិនេះ តុលាការ ECtRH មិនបានពឹងផ្អែកលើតេស្តពិនិត្យស្តីពីបញ្ហាថា "ត្រូវបានប៉ះពាល់ធ្ងន់ធ្ងរ" [69]។

53. ទោះបីយ៉ាងណា តេស្តពិនិត្យនេះត្រូវបានអនុវត្តដោយចៅក្រមបុរេជំនុំជម្រះនៃសាលាក្តីពិសេសសម្រាប់លីបង់ ("STL")សម្រាប់សំណើសុំចូលពិនិត្យសំណុំរឿង នៅក្នុងករណីដែលបុគ្គលម្នាក់មិនមែនជាភាគីនៅក្នុងកិច្ចដំណើរការនីតិវិធី ហើយក៏មិនមែនជាជនរងគ្រោះនៅក្នុងកិច្ចដំណើរការនីតិវិធី។ កាលៈទេសៈពិសេសនៃករណីនេះគឺពាក់ព័ន្ធនឹងបុគ្គលម្នាក់ដែលត្រូវបានចាប់ខ្លួន ហើយឃុំឃាំង ដោយផ្អែកលើមូលដ្ឋាននៃដីកាចាប់ខ្លួនចេញដោយចៅក្រមស៊ើបអង្កេតម្នាក់របស់លីបង់ បន្ទាប់មក ត្រូវបានបញ្ជូនទៅឃុំឃាំងនៅសាលាក្តី STL ហើយគាត់ត្រូវបានឃុំឃាំងនៅក្រោមសមត្ថកិច្ចច្បាប់របស់តុលាការ STL ។ គាត់មិនត្រូវបានចោទដោយរដ្ឋអាជ្ញានៃតុលាការ STL ដើម្បីជំនុំជម្រះឡើយ ហើយក្រោយមក គាត់ត្រូវបានចៅក្រមបុរេជំនុំជម្រះដោះលែង។ បន្ទាប់មក បុគ្គលនោះបានដាក់ពាក្យបណ្តឹងរដ្ឋប្បវេណីនៅចំពោះមុខតុលាការមួយរបស់លីបង់ ដើម្បីប្តឹងអ្នកដែលបាន"ចោទបង្ខូចកេរ្តិ៍ឈ្មោះ"ប្រឆាំងនឹង

---

[68] *រឿងក្តី Foti និង អ្នកផ្សេងទៀត តទល់នឹង អ៊ីតាលី* ថ្ងៃទី ១០ ខែ ធ្នូ ឆ្នាំ ១៩៨២ កថាខណ្ឌ ៥១ *រឿងក្តី Kangasluoma តទល់នឹងហ្វាំឡង់* ថ្ងៃទី ២០ ខែ មករា ឆ្នាំ ២០០៤ កថាខណ្ឌ ២៦។ *សូមមើលផងដែរ រឿងក្តី* McFarlane *តទល់នឹងអៀឡង់* ថ្ងៃទី ១០ ខែ កញ្ញា ឆ្នាំ ២១០ កថាខណ្ឌ ១៤៣ *រឿងក្តី Eckle តទល់នឹងអាល្លឺម៉ង់* ថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ១៩៨២ កថាខណ្ឌ ៧៣ *រឿងក្តី Deweer តទល់នឹងប៊ែលហ្សិក* ថ្ងៃទី ២៧ ខែ កុម្ភៈ ឆ្នាំ ១៩៨០ កថាខណ្ឌ ៤២។

[69] *រឿងក្តី Mooren តទល់នឹងអាល្លឺម៉ង់* ថ្ងៃទី ៩ ខែ កក្កដា ឆ្នាំ ២០០៩ កថាខណ្ឌ ១២៤ *រឿងក្តី Lamy តទល់នឹងប៊ែលហ្សិក* ថ្ងៃទី ៣០ ខែ មីនា ឆ្នាំ ១៩៨៩ កថាខណ្ឌ ២៩។ *សូមមើលផងដែរ រឿងក្តី Nikolova តទល់នឹងប៊ុលហ្គារី* ថ្ងៃទី ២៥ ខែ មីនា ឆ្នាំ ១៩៩៩ កថាខណ្ឌ ៥៨។

គាត់ ដោយ"ការឃុំឃាំងគាត់តាមអំពើចិត្ត"គឺពឹងផ្អែកលើមូលដ្ឋាននៃការចោទនោះ [70] ហើយបានស្នើសុំចូលពិនិត្យមើលសំណុំរឿង ដើម្បីរកភស្តុតាងគាំទ្រការអះអាងរបស់គាត់។ តុលាការលើបង់ បានយល់ឃើញថា ខ្លួនខ្វះយុត្តាធិការសម្រេចលើសំណើរបស់គាត់ដែលស្នើសុំសម្ភារៈភស្តុតាង។

54. ចៅក្រមបុរេជំនុំជម្រះនៃសាលាក្តី STL បានសម្រេចថា បុគ្គលនោះមានសិទ្ធិជូនដំណឹងតុលាការ STL អំពីបញ្ហានេះ [71] ហើយយល់ឃើញថា មានសិទ្ធិជាមូលដ្ឋានមួយដើម្បីទទួលបានសំណងសម្រាប់ផលប៉ះពាល់ទទួលរងដោយសារការឃុំឃាំងខុសច្បាប់ [72]។ ចៅក្រមរូបនេះក៏បានសម្រេចទៀតថា ទោះបីបុគ្គលនោះមិនត្រូវបានចោទជាផ្លូវការនៅចំពោះមុខសាលាក្តី STL ក៏ដោយ ក៏គាត់ "មានសិទ្ធិទទួលបានសិទ្ធិការពារក្តីជាមូលដ្ឋានស្រដៀងនឹងសិទ្ធិដែលផ្តល់ឱ្យជនត្រូវចោទ ដូចជា*សិទ្ធិចូលពិនិត្យមើលសំណុំរឿងព្រហ្មទណ្ឌរបស់គាត់*" [73]។ តុលាការ ECtHR ក៏បានបញ្ជាក់ផងដែរពីភាពសំខាន់នៃការចូលពិនិត្យមើលសំណុំរឿងក្នុងករណីដែលបុគ្គលម្នាក់ត្រូវបានរដ្ឋដាក់ក្នុងពន្ធនាគារ [74]។ នៅក្នុងការអនុវត្ត សូម្បីតែគ្មានការចោទប្រកាន់ជាផ្លូវការក៏ដោយ ក៏ការចូលពិនិត្យមើលសំណុំរឿង ត្រូវបានចាត់ទុកថាជាមធ្យោបាយចាំបាច់ដើម្បីការពារសិទ្ធិរបស់ជនសង្ស័យក្នុងការដេញដោលភាពស្របច្បាប់នៃការឃុំខ្លួនគាត់។

55. ស.ច.ស.អ បានសម្រេចរួចហើយថា ការជូនដំណឹងជាលាយលក្ខណ៍អក្សរ និងការជូនដំណឹងផ្ទាល់មាត់ មិនអាចចាត់ទុកថាបានចោទប្រកាន់ប្រឆាំងនឹងជនសង្ស័យ ដោយត្រឹមត្រូវ និងស្របច្បាប់ឡើយ។ បន្ថែមពីលើនេះទៀត ស.ច.ស.អ មិនយល់ឃើញថា តាមរយៈការទទួលបានការជូនដំណឹងអំពីឋានៈរបស់គាត់ជា "ជនសង្ស័យ" និងអំពីការចោទប្រកាន់ប្រឆាំងនឹង

---

[70] ដីកាសម្រេច *El Sayed* កថាខណ្ឌ ២។

[71] ដីកាសម្រេច *El Sayed* កថាខណ្ឌ ៤២។

[72] ដីកាសម្រេច *El Sayed* កថាខណ្ឌ ៥១។

[73] ដីកាសម្រេច *El Sayed* កថាខណ្ឌ ៥២។

[74] តុលាការ ECtHR *រឿងក្តី Mooren តទល់នឹងអាល្លឺម៉ង់* ថ្ងៃទី ៩ ខែ កក្កដា ឆ្នាំ ២០០៩ កថាខណ្ឌ ១២៤ *រឿងក្តី Lamy តទល់នឹងប៊ែលហ្ស៊ិក* ថ្ងៃទី ៣០ ខែ មីនា ឆ្នាំ ១៩៨៩ កថាខណ្ឌ ២៩។ *សូមមើលផងដែរ រឿងក្តី Nikolova តទល់នឹងប៊ុលហ្គារី* ថ្ងៃទី ២៥ ខែ មីនា ឆ្នាំ ១៩៩៩ កថាខណ្ឌ ៥៨។

គាត់នោះ ជនសង្ស័យមិនត្រូវបានប៉ះពាល់យ៉ាងធ្ងន់ធ្ងរដោយខុសពីវិធានផ្ទៃក្នុង ហើយធានាឱ្យមានការផ្តល់សិទ្ធិ ដែលជនសង្ស័យមិនមានសិទ្ធិទទួលបាន នៅក្នុងដំណាក់កាលនៃកិច្ចដំណើរការនីតិវិធីនេះឡើយ។

56. នៅក្នុងការគាំទ្រសំណើរបស់ខ្លួនស្នើសុំចូលពិនិត្យសំណុំរឿង ក្រុមការពារក្តីជនសង្ស័យបញ្ជាក់ថា កូនក្តីរបស់ខ្លួនមានសុខភាពទ្រុឌទ្រោម ហើយត្រូវបានចុះផ្សាយតាមប្រព័ន្ធផ្សព្វផ្សាយជាតិ និងអន្តរជាតិទាក់ទងនឹងកិច្ចដំណើរការនីតិវិធីប្រឆាំងនឹងគាត់ ហើយត្រូវបានបុគ្គលិកនៃប្រព័ន្ធផ្សព្វផ្សាយចុះជួបជាច្រើនលើក។

57. ស.ច.ស.អ បានធ្វើការពិចារណាយ៉ាងត្រឹមត្រូវលើឥទ្ធិពលដែលការចុះផ្សាយរឿងក្តីនេះតាមរយៈប្រព័ន្ធផ្សព្វផ្សាយអាចមានមកលើជនសង្ស័យ។ តាមទស្សនៈរបស់ ស.ច.ស.អ ការចាប់អារម្មណ៍របស់ប្រព័ន្ធផ្សព្វផ្សាយ មិនមែនជាកត្តាកំណត់មួយសម្រាប់សម្រេចលើសំណើរបស់ក្រុមការពារក្តីជនសង្ស័យឡើយ។ ការចូលពិនិត្យមើលសំណុំរឿង ត្រូវបានទទួលស្គាល់យ៉ាងច្បាស់ថាមានសារៈសំខាន់ណាស់នៅពេលដែលមានការចោទប្រកាន់ (សូមមើលផ្នែក I ខាងលើ) ដើម្បីដេញដោលលើភាពស្របច្បាប់នៃការឃុំខ្លួនតាមបង្គាប់តុលាការ ឬការដកហូតទ្រព្យសម្បត្តិរបស់ជនសង្ស័យណាម្នាក់។ ទោះបីយ៉ាងណា ស.ច.ស.អ យល់ឃើញថា ការចាប់អារម្មណ៍របស់ប្រព័ន្ធផ្សព្វផ្សាយ មិនមានទម្ងន់ដូចករណីខាងលើ ឬក៏តម្រូវឱ្យមានដំណោះស្រាយដូចករណីខាងលើដែរ។ ស.ច.ស.អ ក៏មានការយល់ឃើញដូចខាងលើផងដែរទាក់ទងនឹងការអះអាងរបស់ក្រុមការពារក្តីជនសង្ស័យដែលថា ជនសង្ស័យមានសុខភាពទ្រុឌទ្រោម។

58. សរុបមក ក្នុងករណីដែលមានគ្មានការចោទប្រកាន់ផ្លូវការប្រឆាំងនឹងជនសង្ស័យ គឺគ្មានមូលហេតុណាដែលថាចាំបាច់ត្រូវមានការចូលពិនិត្យមើលសំណុំរឿងដើម្បីការពារសិទ្ធិរបស់ជនសង្ស័យឡើយ។

59. បច្ចុប្បន្ន ជនសង្ស័យត្រូវបានតំណាងដោយមេធាវី និងត្រូវបានជូនដំណឹងគ្រប់គ្រាន់អំពីបទចោទប្រកាន់ប្រឆាំងនឹងគាត់ ហើយដឹងអំពីសិទ្ធិនៅស្ងៀមមិនឆ្លើយតប។ ចំណុចនេះធានាគ្រប់គ្រាន់សម្រាប់សិទ្ធិរបស់គាត់ និងគោរពតាមបទដ្ឋានយុត្តិធម៌អន្តរជាតិបានយ៉ាងពេញលេញ។

## V. សេចក្តីសម្រេចទទួលស្គាល់មេធាវី គឺជាមូលដ្ឋានសម្រាប់ស្នើសុំចូលពិនិត្យមើលសំណុំរឿង

60. ចុងក្រោយបំផុត នៅក្នុងលិខិតចុះថ្ងៃទី ១៣ ខែ មិថុនា ឆ្នាំ ២០១៣ ក្រុមការពារក្តីជនសង្ស័យ ពឹងផ្អែកលើសេចក្តីសម្រេចទទួលស្គាល់មេធាវីដើមបណ្តឹងរដ្ឋប្បវេណី ចេញថ្ងៃទី ១ ខែ មេសា ឆ្នាំ ២០១៣ ("សេចក្តីសម្រេចទទួលស្គាល់មេធាវីដើមបណ្តឹងរដ្ឋប្បវេណី" [75] ហើយបញ្ជាក់ថា ដោយផ្អែកលើមូលដ្ឋាននោះ *"ច្បាស់ណាស់ថា មេធាវីដែលត្រូវបានទទួលស្គាល់ ត្រូវតែបាន អនុញ្ញាតឱ្យចូលពិនិត្យសំណុំរឿង"* [76]។ សេចក្តីសម្រេចទទួលស្គាល់មេធាវីដើមបណ្តឹង រដ្ឋប្បវេណី បញ្ជាក់យ៉ាងច្បាស់ថា "មេធាវីដែលត្រូវបានទទួលស្គាល់មានសិទ្ធិពិនិត្យ និង ថតចម្លងឯកសារដើមនៃសំណុំរឿងស្តីពីការស៊ើបអង្កេត <u>ដែលកូនក្តីរបស់ខ្លួនជាភាគីម្នាក់ (សង្កត់ន័យបន្ថែម)</u>"។ ជនសង្ស័យម្នាក់មិនមែនជាភាគីមួយនៅក្នុងកិច្ចដំណើរការនីតិវិធីឡើយ ដូច្នេះហើយសេចក្តីសម្រេចទទួលស្គាល់មេធាវីដើមបណ្តឹងរដ្ឋប្បវេណី មិនគាំទ្រតាមសំណើ របស់ក្រុមការពារក្តីជនសង្ស័យឡើយ។ ដោយមានមូលហេតុដូចគ្នានេះ ស.ច.ស.អ ច្រានចោលទឡ្ហីករណ៍ដែលថា ការបដិសេធមិនអនុញ្ញាតឱ្យជនសង្ស័យណាម្នាក់ចូលពិនិត្យ មើលសំណុំរឿង គឺជាការបញ្ជូន *"សាររំខាន... អំពីឋានានុក្រមរបស់ភាគី"*។

## VI. សេចក្តីសន្និដ្ឋាន

61. ស.ច.ស.អ ពិចារណាឡើងវិញលើការជូនដំណឹងជាលាយលក្ខណ៍អក្សរ និងការជូនដំណឹង ផ្ទាល់មាត់ ហើយលុបចោលការជូនដំណឹងទាំងនោះត្រង់ចំណុចដែលថា ការជូនដំណឹង ទាំងនោះអនុញ្ញាតឱ្យជនសង្ស័យចូលពិនិត្យមើលសំណុំរឿង។

62. ជនសង្ស័យ មិនមែនជាជនត្រូវចោទ ដូច្នេះហើយទើបមិនមែនជាភាគីណាមួយឡើយនៅក្នុង ដំណាក់កាលនេះនៃកិច្ចដំណើរការនីតិវិធី។ បច្ចុប្បន្ននេះ គ្មានមូលហេតុណាផ្សេងទៀតដែល ធានាថា ជនសង្ស័យអាចចូលពិនិត្យមើលសំណុំរឿងបានឡើយ។ ដោយសារមូលហេតុ

---

[75] សំណុំរឿង ០០៤ ឯកសារ D126 *សេចក្តីសម្រេចទទួលស្គាល់មេធាវីដើមបណ្តឹងរដ្ឋប្បវេណី* ចុះថ្ងៃទី ១ ខែ មេសា ឆ្នាំ ២០១៣។

[76] លិខិតចុះថ្ងៃទី ១៣ ខែ មិថុនា ឆ្នាំ ២០១៣ ទំព័រ ២។

ទាំងនេះ សំណើរបស់ក្រុមការពារក្តីជនសង្ស័យដែលស្នើសុំចូលរួមការស៊ើបអង្កេត ត្រូវតែបដិសេធផងដែរ ។

**តាមសំអាងហេតុខាងលើនេះ** ខ្ញុំ **MARK B. HARMON ៖**

63. **ពិចារណាឡើងវិញ** លើការជូនដំណឹងជាលាយលក្ខណ៍អក្សរ និងការជូនដំណឹងផ្ទាល់មាត់ ហើយ លុបចោលការអនុញ្ញាតដែលឲ្យជនសង្ស័យចូលពិនិត្យមើលសំណុំរឿង។

64. **បដិសេធ** សំណើដែលបានស្នើសុំនៅក្នុងសំណើបន្ទាន់ លិខិតបន្ថែម និង លិខិតចុះថ្ងៃទី ១៧ ខែ មិថុនា ឆ្នាំ ២០១៣។

65. **បដិសេធ** សំណើដែលបានស្នើសុំនៅក្នុងលិខិតចុះថ្ងៃទី ១២ ខែ មីនា ឆ្នាំ ២០១៣។

ធ្វើនៅភ្នំពេញ ថ្ងៃទី៣១ ខែកក្កដា ឆ្នាំ ២០១៣

**Mark B. Harmon**
**សហចៅក្រមស៊ើបអង្កេតអន្តរជាតិ**
International Co-Investigating Judge
Co-juge d'instruction international